


**រូបទី ៧៤ : កំណើនការងារក្នុងស្រុកសៀមរាប**

## ១១.២ ក្របខ័ណ្ឌសកម្មភាពតាមតំបន់

### ១១.២.១ លក្ខណ:តំបន់

ក្រុងសៀមរាប/អង្គរធ្លាប់ជាតំបន់ដ៏ធំនៅឥណ្ឌូចិនភាគខាងក្រោម។ ក្រុងនេះគឺជារដ្ឋធានីនៃសន្តិវង្សអង្គររវាងពាក់កណ្តាលសតវត្សរ៍ទី៨ និងឆ្នាំ១៤៣១ មុនគ្រីស្តសករាជ។ នៅពេលនោះ គេបាននិយាយថា "អង្គរគឺជាមជ្ឈមណ្ឌលនៃផ្លូវទាំងអស់ "។ ចាប់តាំងពីការដួលរលំនៃសម័យសន្តតិវង្ស ទឹកដីនៃប្រទេសកម្ពុជារងការរំលោភបំពានពីប្រទេសថៃ និងវៀតណាម។ ប្រទេសដ៏មានអំណាចទាំងពីរនេះបានមានឥទ្ធិពលយ៉ាងខ្លាំងទៅលើនយោបាយ និងសេដ្ឋកិច្ចនៃប្រទេសកម្ពុជាអស់រយ:ពេលយ៉ាងយូរ។

នៅពេលបច្ចុប្បន្ន ប្រវត្តិដ៏យូរលង់នៃការប្រកួតប្រជែងបែបអមិត្តជាមួយនឹងប្រទេសក្នុងតំបន់ត្រូវបានកែប្រែទាំងស្រុង។ ការចូលជាសមាជិកភាពនៃអង្គការពាណិជ្ជកម្មពិភពលោក និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាននឹងជួយដល់ការកាត់បន្ថយរបាំងសេដ្ឋកិច្ចលើទំនិញឆ្លងកាត់ព្រំដែននៅតាមប្រទេសទាំងឡាយនៅឥណ្ឌូចិន។ ច្រកធ្វើដំណើរ[5] រវាងទីក្រុងបាងកក-ទីក្រុងភ្នំពេញ-ទីក្រុងហូជីមិញនឹងពង្រឹងវត្តមានប្រទេសកម្ពុជាក្នុងសេដ្ឋកិច្ចអន្តរជាតិ។ ការអភិវឌ្ឍន៍ច្រកសេដ្ឋកិច្ចខាងត្បូង (SEC)នឹងធ្វើឱ្យមានការកែប្រែមុខមាត់បេតិកភណ្ឌអង្គរពីកន្លែងទាក់ទាញ សាមញ្ញទៅជាមជ្ឈមណ្ឌលនៃបណ្តាញទេសចរណ៍ ដោយសារហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មផ្សេងៗ។ ការកែប្រែដូចនេះ មិនត្រឹមតែធ្វើឱ្យមានការរីកចំរើនដល់តំបន់ក្រុងសៀមរាប/អង្គរប៉ុណ្ណោះទេ តែនាំឱ្យមានការកែប្រែមុខមាត់ខេត្តសៀមរាបទាំងមូលដោយសារតែឥទ្ធិពលសេដ្ឋកិច្ច។

រូបទី៧៦បង្ហាញពីរចនាសម្ព័ន្ធតំបន់នៃប្រទេសកម្ពុជា។ សៀមរាបស្ថិតនៅផ្នែកពាយព្យនៃតំបន់ទំនាប ដែលលាតសន្ធឹងពីទីជំរាលទាបរវាងភ្នំគូលេន និងបឹងទន្លេសាប។

[5] ច្រកនេះត្រូវបានគេហៅម្យ៉ាងទៀតថាជាច្រកសេដ្ឋកិច្ចភាគខាងត្បូង (SEC) ។ ផ្លូវដ៏សំខាន់នេះតភ្ជាប់ក្រុងបាងកក បាត់ដំបង ភ្នំពេញ និងទីក្រុងហូជីមិញ។ បើទោះបីជាផ្លូវជាតិលេខ ៦មិនទាន់អាចប្រើសំរាប់ឆ្លងកាត់តំបន់ទាំងអស់ក៏ដោយ ក៏ផ្លូវនេះគឺជា ជំរើសដ៏សំខាន់ក្រៅពីផ្លូវជាតិលេខ ៥។

នៅក្នុងប្រទេសកម្ពុជា តំបន់ទំនាបដែលមានកំពស់ទាបជាង ៣០ ម៉ែត្រលើនីវ៉ូសមុទ្រ ដែលមានចំនួន៤០%នៃផ្ទៃដីសរុបរបស់ប្រទេសកម្ពុជា មានប្រជាជនរស់នៅប្រមាណជា៩០% ហើយមានរដ្ឋធានីប្រវត្តិសាស្ត្រមួយចំនួនស្ថិតនៅក្នុងតំបន់ទំនាបទាំងនេះ។ តំបន់ទំនាបមានពីរតំបន់ធំៗគឺ តំបន់ដីសណ្តរទន្លេមេគង្គ និងតំបន់ជាប់បឹងទន្លេសាប។




ប្រភព : ក្រុមសិក្សា JICA

**រូបទី ៧៥ : តំបន់សំខាន់ៗពីរ និងបណ្តាញផ្លូវដឹកជញ្ជូនក្នុងប្រទេសកម្ពុជា**

ក្រុងសៀមរាប/អង្គរ គឺជាក្រុងមួយក្នុងចំណោមក្រុងបុរាណមួយចំនួននៅអាស៊ីដែលបានដាក់បញ្ចូលទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោករបស់ UNESCO។ តំបន់ជាប្រវត្តិសាស្ត្រនេះឆ្លុះបញ្ចាំងពីរចនាសម្ព័ន្ធមួយរបស់ប្រទេសកម្ពុជា។ គេនិយាយថា ក្រុងអង្គរ កំពង់ធំ និងព្រះវិហារអាចរួមបញ្ចូលគ្នាបង្កើតជាមុំត្រីកោណប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលមានក្រុងអង្គរជាមជ្ឈមណ្ឌលគ្រឹះនៃអាណាចក្រខ្មែរអស់រយៈពេលយ៉ាងយូរ។

### ១១.២.២ របាយប្រជាជន

ក្រៅពីចំនួនប្រជាជនដែលបានព្យាករណ៍សំរាប់ឆ្នាំ២០១២ និង២០២០ ផែនការនេះបានធ្វើការគិតទុកពីទំរង់នៃរបាយប្រជាជន ដើម្បីស្វែងយល់គំនិតអំពី "ក្រុងទំនើប"។ គំនិតជាមូលដ្ឋានសំរាប់ក្របខ័ណ្ឌសកម្មភាពលើការបែងចែកចំនួនប្រជាជនគឺត្រូវពង្រីកតំបន់ក្រុងនៃស្រុកសៀមរាបដើម្បីឱ្យមានដង់ស៊ីតេប្រជាជនសមស្រប។ ជាងនេះទៀត ការពង្រីកតំបន់ក្រុងគួតែធ្វើឡើងទៅកាន់ទិសខាងត្បូង។ គេត្រូវតែគ្រោងថាតំបន់តាំងទីលំនៅថ្មីត្រូវតែមានដង់ស៊ីតេប្រជាជនប្រមាណជា៤០ - ៦០ នាក់ក្នុងមួយហិចតា[6]។

ក្រៅពីនេះ ត្រូវគិតបញ្ចូលនូវចំណុចផ្សេងៗទៀតដូចខាងក្រោម :

[6] សូមអានព័ត៌មានលំអិតផ្នែក II ក្នុងជំពូក ១។

- ដង់ស៊ីតេប្រជាជនក្នុងតំបន់ក្រុងនៃស្រុកសៀមរាបនឹងត្រូវកំណត់យកប្រមាណជា ៥០ នាក់ក្នុងមួយហិចតា នៅទូទាំងតំបន់ក្រុងបច្ចុប្បន្ន និងតំបន់ក្រុងថ្មី។
- នៅឆ្នាំ២០១២ តំបន់នៅខាងក្នុងនៃផ្លូវជុំវិញវង់តូចដែលបានគិតទុកសន្មតថាជាតំបន់ក្រុង ហើយនៅឆ្នាំ ២០២០ ការពង្រីកចេញពីតំបន់នេះនឹងត្រូវធ្វើឡើងនៅតំបន់ភាគខាងកើតនៃផ្លូវជុំវិញ។
- នៅក្នុងតំបន់មួយចំនួនដែលមានដង់ស៊ីតេនៃការតាំងទីលំនៅខ្ពស់នៅពេលបច្ចុប្បន្ន ដែលស្ថិតនៅភាគឦសាន របស់ក្រុង ដង់ស៊ីតេប្រជាជននៅពេលអនាគតនឹងមានចំនួនទាបជាងនៃចំនួនប្រជាជននាពេលបច្ចុប្បន្ន ដោយផ្អែកលើការប៉ាន់ស្មានថា ការប្រែប្រួលទីប្រជុំជនអាចនឹងកើតមាន។
- ជារួម របាយប្រជាជនត្រូវបានកែសំរួលដើម្បីកាត់បន្ថយភាពខុសគ្នាឱ្យនៅតិចបំផុតឱ្យស្របតាមគោលការណ៍ណែនាំដែលកំពុងតែគិតពិចារណាដោយអាជ្ញាធរអប្សរា។

របាយប្រជាជននៅឆ្នាំ ២០០៤ ២០១២ និង ២០២០របស់ស្រុកសៀមរាបនឹងត្រូវបញ្ចូលក្នុងតារាង៣៩ និងមានបកស្រាយក្នុងរូបទី៧៧ ដល់៧៩។

របាយប្រជាជននេះត្រូវបានប្រើប្រាស់ជាទំរង់រួមសំរាប់ការរៀបចំហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានផ្សេងៗ ដូចជា អគ្គិសនី ការផ្គត់ផ្គង់ទឹក និងប្រព័ន្ធបង្ហូរទឹក។




ប្រភព៖ ក្រុមសិក្សា JICA

រូបទី ៧៦ ៖ ដង់ស៊ីតេប្រជាជននាពេលបច្ចុប្បន្ន ២០០៤




ប្រភព : ក្រុមសិក្សា JICA

រូបទី ៧៧ : ដង់ស៊ីតេប្រជាជន ឆ្នាំ ២០១២




ប្រភព : ក្រុមសិក្សា JICA

រូបទី ៧៨ : ដង់ស៊ីតេប្រជាជន ២០២០ )

## តារាង ៣៩ : ក្របខ័ណ្ឌសកម្មភាពសំរាប់ចំនួនប្រជាជននៃស្រុកសៀមរាប (១/២)

| ឃុំ | ឈ្មោះភូមិ | ទំហំ (ហ.ត) | ចំនួនប្រជាជន | | | ដង់ស៊ីតេ (នាក់/ហិចតា) | | |
|---|---|---|---|---|---|---|---|---|
| | | | 2004 | 2012 | 2020 | 2004 | 2012 | 2020 |
| ស្លក្រាម | ស្លក្រាម | 13,6 | 1.870 | 1.520 | 1.421 | 137,2 | 111,5 | 104,2 |
| | បឹងដូនប៉ា | 90,6 | 2.801 | 2.991 | 3.631 | 30,9 | 33,0 | 40,1 |
| | ចុងកៅស៊ូ | 427,5 | 8.196 | 9.714 | 11.805 | 19.2 | 22.7 | 27,6 |
| | ជាគីបុំ (តំបន់ក្រុង) | 119,4 | 2.611 | 3.115 | 3.814 | 21,9 | 26,1 | 31,9 |
| | ជាគីបុំ (តំបន់ជនបទ) | 57,4 | 198 | 214 | 232 | 3,4 | 3,7 | 4,0 |
| | បន្ទាយចាស់ | 29,7 | 5.573 | 5.071 | 4.481 | 187,7 | 170,8 | 150,9 |
| | ទ្រាំង | 489,2 | 3.122 | 3.122 | 3.122 | 6,4 | 6,4 | 6,4 |
| | មណ្ឌលបី | 73,0 | 4.912 | 5.010 | 5.110 | 67,3 | 68,6 | 70,0 |
| | សរុប | 1300,4 | 29.283 | 30.757 | 33.616 | 22,5 | 23,7 | 25,8 |
| | សរុបក្នុងតំបន់ក្រុង | 326,4 | 17.767 | 17.707 | 18.457 | 54,4 | 54,2 | 56,5 |
| ស្វាយដង្គំ | ក្រាជីយ (តំបន់ក្រុង) | 26,8 | 143 | 203 | 753 | 5,3 | 7,6 | 28,1 |
| | ក្រាជីយ (តំបន់ជនបទ) | 110,4 | 569 | 616 | 667 | 5,2 | 5,6 | 6,0 |
| | កាប់ក្រាក | 160,7 | 1.373 | 1.450 | 1.520 | 8,5 | 9,0 | 9,5 |
| | គោកក្រសាំង | 2442,1 | 789 | 907 | 1.200 | 0,3 | 0,4 | 0,5 |
| | ស្វាយព្រៃ | 90,0 | 871 | 880 | 890 | 9,7 | 9,8 | 9,9 |
| | ប៉ុំបុស | 156,2 | 771 | 887 | 1.153 | 4,9 | 5,7 | 7,4 |
| | ថ្មី (តំបន់ក្រុង) | 75,1 | 598 | 2.044 | 3.466 | 8,0 | 27,2 | 46,2 |
| | ថ្មី (តំបន់ជនបទ) | 60,8 | 157 | 170 | 184 | 2,6 | 2,8 | 3,0 |
| | ស្វាយដង្គំ (ក្រុង) | 86,0 | 1.347 | 2.850 | 4.307 | 15,7 | 33,1 | 50,1 |
| | ស្វាយដង្គំ (ជនបទ) | 137,2 | 335 | 363 | 393 | 2,4 | 2,6 | 2,9 |
| | សាលាកំរើក | 164,2 | 5.751 | 6.400 | 7.811 | 35,0 | 39,0 | 47,6 |
| | ក្រួស (ក្រុង) | 63,7 | 2.455 | 2.760 | 3.060 | 38,5 | 43,3 | 48,0 |
| | ក្រួស (ជនបទ) | 90,7 | 661 | 715 | 775 | 7,3 | 7,9 | 8,5 |
| | វិហារចិន | 65,9 | 4.884 | 5.560 | 7.228 | 74,1 | 84,4 | 109,7 |
| | ស្ទឹងថ្មី (ក្រុង) | 86,1 | 3.191 | 3.858 | 5.081 | 37,1 | 44,8 | 59,0 |
| | ស្ទឹងថ្មី (ជនបទ) | 46,7 | 85 | 92 | 100 | 1,8 | 2,0 | 2,1 |
| | មណ្ឌលមួយ | 18,1 | 2.871 | 2.681 | 2.500 | 158,8 | 148,3 | 138,3 |
| | មណ្ឌលពីរ | 35,8 | 336 | 500 | 750 | 9,4 | 14,0 | 21,0 |
| | តាភុល | 114,6 | 2.895 | 3.471 | 4.911 | 25,3 | 30,3 | 42,9 |
| | សរុប | 4031,0 | 30.082 | 36.407 | 46.749 | 7,5 | 9,3 | 11,8 |
| | សរុបតំបន់ក្រុង | 736,3 | 24.471 | 30.327 | 39.867 | 33,2 | 41,2 | 54,1 |
| គោកចាក | ត្រពាំងសេះ (ក្រុង) | 128,9 | 4.576 | 4.536 | 4.494 | 35,5 | 35,2 | 34,9 |
| | ត្រពាំងសេះ (ជនបទ) | 112,7 | 475 | 515 | 557 | 4,2 | 4,6 | 4,9 |
| | វាល (ក្រុង) | 33,7 | 497 | 497 | 497 | 14,7 | 14,7 | 14,7 |
| | វាល (ជនបទ) | 831,4 | 1.900 | 1.900 | 1.900 | 2,3 | 2,3 | 2,3 |
| | ទក្សិណត្បូង (ក្រុង) | 63,1 | 1.571 | 1.921 | 2.671 | 24,9 | 30,4 | 42,3 |
| | ទក្សិណត្បូង (ជនបទ) | 79,3 | 571 | 618 | 670 | 7,2 | 7,8 | 8,4 |
| | គោកចាន | 445,5 | 1.056 | 1.056 | 1.056 | 2,4 | 2,4 | 2,4 |
| | ជីវៀង | 142,3 | 1.287 | 1.287 | 1.287 | 9,0 | 9,0 | 9,0 |
| | គោកបេង | 696,7 | 1.117 | 1.117 | 1.117 | 1,6 | 1,6 | 1,6 |
| | គោកធ្លាក | 698,2 | 2.327 | 2.327 | 2.327 | 3,3 | 3,3 | 3,3 |
| | ទទរក្រៅ | 579,6 | 2.738 | 2.738 | 2.738 | 4,7 | 4,7 | 4,7 |
| | សរុប | 3811,3 | 18.115 | 18.512 | 19.314 | 4,8 | 4,9 | 5,1 |
| | សរុបតំបន់ក្រុង | 225,7 | 6.644 | 6.954 | 7.662 | 29,4 | 30,8 | 33,9 |
| សាលាកំរើក | វត្តបូ | 253,0 | 4.918 | 10.847 | 15.891 | 19,4 | 42,9 | 62,8 |
| | វត្តស្វាយខាងលិច | 67,1 | 1.861 | 2.558 | 3.582 | 27,7 | 38,1 | 53,4 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | វត្តស្វាយខាងកើត | 81,7 | 2.267 | 3.117 | 4.363 | 27,7 | 38,2 | 53,4 |
| | វត្តដំណាក់ខាងលិច | 37,0 | 2.195 | 2.220 | 2.230 | 59,3 | 60,0 | 60,3 |
| | វត្តដំណាក់ខាងកើត | 75,2 | 1.378 | 3.637 | 4.535 | 18,3 | 48,4 | 60,3 |
| | សាលាកំរើក | 61,2 | 1.319 | 2.160 | 3.141 | 21,5 | 35,3 | 51,3 |
| | ជល្លង | 58,0 | 803 | 1.700 | 2.338 | 13,8 | 29,3 | 40,3 |
| | ការវៀន | 117,5 | 1.895 | 3.700 | 5.041 | 16,1 | 31,5 | 42,9 |
| | ព្រៃកងក្រើង | 90,0 | 593 | 2.160 | 3.024 | 6,6 | 24,0 | 33,6 |
| | សរុប | 840,6 | 17.229 | 32.099 | 44.145 | 20,5 | 37,1 | 51,5 |
| | សរុបតំបន់ក្រុង | 840,6 | 17.229 | 32.099 | 44.145 | 20,5 | 38,2 | 52,5 |

ប្រភព : ក្រុមសិក្សា JICA

កំណត់ចំណាំ :

- តួលេខដែលមានស្រមោលបង្ហាញតំបន់ក្រុងនៅពេលអនាគត
- ពុំមានទិន្នន័យសំរាប់ភូមិចុងឃ្នាសទេ។

**តារាង ៤០ : ក្របខ័ណ្ឌសកម្មភាពសំរាប់ចំនួនប្រជាជននៃស្រុកសៀមរាប (២/២)**

| ឈ្មោះឃុំ | ឈ្មោះភូមិ | ទំហំ (ហ.ត) | ចំនួនប្រជាជន | | | ដង់ស៊ីតេ (នាក់/ហិចតា) | | |
|---|---|---|---|---|---|---|---|---|
| | | | 2004 | 2012 | 2020 | 2004 | 2012 | 2020 |
| នគរធំ | រំហាល | 1.878,4 | 1.346 | 1.346 | 1.346 | 0,7 | 0,7 | 0,7 |
| | ស្រះស្រង់ជើង | 788,5 | 928 | 928 | 928 | 1,2 | 1,2 | 1,2 |
| | ស្រះស្រង់ត្បូង | 731,4 | 556 | 556 | 556 | 0,8 | 0,8 | 0,8 |
| | ក្រវ៉ាន់ | 691,7 | 892 | 892 | 892 | 1,3 | 1,3 | 1,3 |
| | អារក្សស្វាយ | 233,8 | 493 | 493 | 493 | 2,1 | 2,1 | 2,1 |
| | អញ្ចង់ | 1.164,5 | 861 | 861 | 861 | 0,7 | 0,7 | 0,7 |
| | សរុប | 5.488,2 | 5.076 | 5.076 | 5.076 | 0,9 | 0,9 | 0,9 |
| ជ្រាវ | ជ្រាវ | 1.015,1 | 860 | 929 | 1.003 | 0,8 | 0,9 | 1,0 |
| | ខ្នារ | 666,1 | 2.686 | 7.320 | 13.550 | 4,0 | 11,0 | 20,3 |
| | បុសព្រលាញ់ | 277,7 | 1.263 | 1.364 | 1.910 | 4.5 | 4,9 | 6,9 |
| | តាចេក | 113,4 | 631 | 681 | 736 | 5,6 | 6,0 | 6,5 |
| | វាល | 4.063,6 | 1.298 | 1.402 | 1.514 | 0,3 | 0,3 | 0,4 |
| | ព្រសាំង | 285,0 | 1.065 | 1.385 | 3.250 | 3,7 | 4,9 | 11,4 |
| | បឹង | 159,3 | 568 | 613 | 663 | 3,6 | 3,8 | 4,2 |
| | សរុប | 6.580,2 | 8.371 | 13.694 | 22.626 | 1,3 | 2,1 | 3,4 |
| ចុងឃ្នាស | ភូមិមួយ | 0 | 999 | 1.079 | 1.187 | N.A | N.A | N.A |
| | ភូមិពីរ | 0 | 619 | 669 | 735 | N.A | N,A, | N.A |
| | ភូមិបី | 0 | 723 | 781 | 859 | N.A | N.A | N.A |
| | ភូមិបួន | 0 | 754 | 814 | 896 | N.A | N.A | N.A |
| | ភូមិប្រាំ | 0 | 517 | 558 | 614 | N.A | N.A | N.A |
| | ភូមិប្រាំមួយ | 0 | 731 | 789 | 868 | N.A | N.A | N.A |
| | ភូមិប្រាំពីរ | 0 | 2.053 | 2.217 | 2.439 | N.A | N.A | N.A |
| | សរុប | 0 | 6.396 | 6.907 | 7.598 | N.A | N.A | N.A |
| សម្បួរ | ក្តៅ | 46,8 | 682 | 716 | 920 | 14,6 | 15,3 | 19,7 |
| | សម្បួរ | 146,9 | 765 | 803 | 1.059 | 5,2 | 5,5 | 7,2 |
| | វាល | 422,1 | 579 | 608 | 800 | 1,4 | 1,4 | 1,9 |
| | ព្រៃ | 1.950,3 | 633 | 665 | 875 | 0,3 | 0,3 | 0,4 |
| | តាគង់ | 131,0 | 605 | 635 | 856 | 4,6 | 4,8 | 6,5 |
| | សរុប | 2.697,0 | 3.264 | 3.427 | 4.510 | 1,2 | 1,3 | 1,7 |
| សៀមរាប | ពោធិ៍ | 64,5 | 2.739 | 3.013 | 3.200 | 42,4 | 46,7 | 49,6 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ភ្នំក្រោម | 3.810,7 | 2.581 | 2.839 | 3.123 | 0,7 | 0,7 | 0,8 |
| | ប្រលៃ | 471,2 | 760 | 836 | 920 | 1,6 | 1,8 | 2,0 |
| | កាកកញ | 93,2 | 2.409 | 2.650 | 2.915 | 25,8 | 28,4 | 31,3 |
| | ក្រសាំងរលើង | 500,2 | 776 | 854 | 939 | 1,6 | 1,7 | 1,9 |
| | ស្ពានថ្មៅ | 85,1 | 2.367 | 2.604 | 2.864 | 27,8 | 30,6 | 33,7 |
| | អារ៉ាញ់ | 211,4 | 3.301 | 3.631 | 3.994 | 15,6 | 17,2 | 18,9 |
| | ទន្រ្សៀត | 278,9 | 1.195 | 1.315 | 1.446 | 4,3 | 4,7 | 5,2 |
| | សរុប | 5.515,3 | 16.128 | 17.742 | 19.401 | 2,9 | 3,2 | 3,5 |
| ស្រង៉ែ | កសិកម្ម | 110,7 | 1.179 | 1.179 | 1.179 | 10,6 | 10,6 | 10,6 |
| | ថ្មល | 150,3 | 1.293 | 1.422 | 1.872 | 8,6 | 9,5 | 12,5 |
| | ទការធំ | 141,7 | 516 | 675 | 1.274 | 3,6 | 4,8 | 9,0 |
| | វិព្រធំ | 96,5 | 624 | 686 | 903 | 6,5 | 7,1 | 9,4 |
| | ប្រស៊ែ | 89,0 | 840 | 860 | 880 | 9,4 | 9,7 | 9,9 |
| | ចន្លុង | 84,6 | 712 | 740 | 840 | 8,4 | 8,7 | 9,9 |
| | តាយាក | 3.065,4 | 458 | 504 | 663 | 0,1 | 0,2 | 0,2 |
| | សរុប | 3.738,3 | 5.622 | 6.066 | 7.611 | 1,5 | 1,6 | 2,0 |
| | សរុបតំបន់ក្រុង | 261,1 | 2.472 | 2.601 | 3.051 | 9,5 | 10,0 | 11,7 |
| | សរុបរួម | 34.003 | 139.566 | 170.687 | 210.646 | 4,1 | 5,0 | 6,2 |
| | សរុបរួមតំបន់ក្រុង | 2.390,2 | 68.583 | 89.688 | 113.182 | 28,7 | 37,5 | 47,4 |

**ប្រភព: ក្រុមសិក្សា JICA**

**កំណត់ចំណាំ :**

- តួលេខដែលមានស្រមោលបង្ហាញតំបន់ក្រុងនៅពេលអនាគត
- ពុំមានទិន្នន័យសំរាប់ឃុំចុងឃ្នាសទេ ។

### ១១.២.៣ ការប្រើប្រាស់ដី

ការកំណត់ក្របខ័ណ្ឌសកម្មភាពសំរាប់ការប្រើប្រាស់ដី គឺជាការងារផ្អែកលើការប៉ាន់ស្មានជាងក្របខ័ណ្ឌសកម្មភាពដទៃទៀត ពីព្រោះដីនៅតំបន់ក្រុងភាគច្រើនគឺត្រូវបានគេប្រើប្រាស់ចំរុះ ។ ផែនការប្រើប្រាស់ដីក្នុងការសិក្សាក្រុងសៀមរាប /អង្គរនេះត្រូវបានគិតគូររហូតដល់ឆ្នាំ២០២០ ។

ដើម្បីគ្រប់គ្រងការពង្រីកក្រុង និងការអភិវឌ្ឍន៍ឱ្យសមស្របទៅនឹងផែនការប្រើប្រាស់ដី គឺត្រូវតែមានការត្រួតពិនិត្យសំណង់ថ្មីៗដោយផ្អែកលើអត្រាគ្របដណ្តប់ ចំនួនជាន់នៃអគ្រាតំបន់ និង/ឬកំពស់អាគារ ។ ការត្រួតពិនិត្យត្រូវតែអនុវត្តចំពោះសំណង់ថ្មីៗនៅក្នុង "តំបន់ពង្រីកក្រុង" ដែលបានកំណត់សំរាប់ឆ្នាំ ២០២០ ។

ដើម្បីធ្វើឱ្យសំរេចនូវគោលគំនិតទីក្រុងទំនើបក្នុងស្រុកសៀមរាប តំបន់នានាដែលស្ថិតនៅខាងក្នុងផ្លូវជុំវិញដែលបានស្នើ និងស្ថិតនៅខាងត្បូងផ្លូវជាតិលេខ៦ ត្រូវតែចាត់ទុកជាតំបន់អាទិភាព ។ ចំណែកឯតំបន់ក្រៅពីតំបន់អាទិភាពនេះត្រូវតែចាត់ទុកជាតំបន់សំរាប់ផ្អែកឯកជន ។ ការអភិវឌ្ឍន៍ក្រុងគួរតែអនុញ្ញាតក្នុងកំរិតមួយសមស្រប និងស្របតាមលក្ខណៈបរិស្ថានក្រុង និងមានផែនការច្បាស់លាស់ ។

ទោះបីប្រទេសកម្ពុជាគ្មានការបែងចែកប្រភេទនៃការប្រើប្រាស់ដីក្នុងក្រុងជាផ្លូវការក៏ដោយ ក៏ការសិក្សានេះសំរេចបង្កើតប្រព័ន្ធនៃការបែងចែកការប្រើប្រាស់ដី ដោយសហការការងារជាមួយនឹងគំរោង ASIA Urbs និងស្រុកសៀមរាប (អានផ្អែកទី៣នៃជំពូក១ សំរាប់ព័ត៌មានលំអិត) ។

ជាលទ្ធផល ពង្រាងផែនការប្រើប្រាស់ដីធ្លីមួយដែលមានបង្ហាញនៅក្នុងរូបទី៨០ ត្រូវបានដកស្រង់ចេញពីគំនិតមូលដ្ឋានទាក់ទងទៅនឹងក្របខ័ណ្ឌសកម្មភាពសំរាប់រាយប្រជាជន និងពីទំរង់នៃការប្រើប្រាស់ដីធ្លីនាពេលបច្ចុប្បន្ន។ ផែនការនៃការប្រើប្រាស់ដីនេះនឹងត្រូវរៀបចំឡើងសំរាប់ធ្វើជាគោលការណ៍ណែនាំ។ ផែនការនេះនឹងគ្មានប្រសិទ្ធភាពអ្វីឡើយ លុះត្រាតែមានការបង្កើតវិធានការគ្រប់គ្រងការប្រើដីធ្លីសមស្របមួយនៅក្នុងប្រទេស។




ប្រភព : ក្រុមសិក្សា JICA

**រូបទី ៧៩ : ពង្រាងផែនការប្រើប្រាស់ដីធ្លី**

## ១១.៣ ក្របខ័ណ្ឌសកម្មភាពសំរាប់វិស័យទេសចរណ៍

### ១១.៣.១ ចំនួននៃកំណើនមកដល់របស់អ្នកទេសចរ

តាមការព្យាករណ៍ ចំនួនអ្នកទេសចរពីឆ្នាំ២០១២ (រយៈពេលមធ្យម) ដល់ឆ្នាំ ២០២០ (រយៈពេលវែង) សន្មតដោយសេណារីយូ (ករណី) ពីរដូចខាងក្រោម :

ការព្យាករណ៍តាមនិន្នាការ : ករណីកំណើនតាមនិន្នាការ (ដោយគ្មានផែនការមេ) : ករណីនេះគឺថា សៀមរាបនឹងនៅតែបន្តទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិ និងការវិនិយោគឯកជនលើវិស័យទេសចរណ៍មកកាន់សៀមរាប ដែលការនេះបង្កផលប៉ះពាល់អវិជ្ជមានដល់បរិវេណអង្គរ និងតំរូវការកាន់តែច្រើនឡើងនូវហេដ្ឋារចនាសម្ព័ន្ធដើម្បីទ្រទ្រង់ឧស្សាហកម្មទេសចរណ៍។

ការព្យាករណ៍ដោយមានអន្តរាគមន៍ពីគោលនយោបាយ : ករណីអភិរក្សអង្គរវត្ត (ដោយមានផែនការមេ) : ករណីនេះត្រូវតែធ្វើការគ្រប់គ្រងការអភិវឌ្ឍន៍សណ្ឋាគារប្រាសចាកពីផែនការកាត់បន្ថយផលប៉ះពាល់ដល់បរិវេណប្រាសាទអង្គរ

វត្តឱ្យនៅតិចបំផុត។ ជាមួយគ្នានេះដែរ ចំនួននៃអ្នកទេសចរបរទេសនៅឆ្នាំ២០២០ នឹងមិនលើសពីសមត្ថភាពផ្តល់សេវាកម្មនៃអាកាសយានដ្ឋានសៀមរាបបច្ចុប្បន្ននេះ។

ចំនួនអ្នកទេសចរដែលបានប៉ាន់ស្មានពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១០ ដែលផ្អែកលើលើនិន្នាការកំណើនរវាងការព្យាករណ៍តាមនិន្នាការ និងការព្យាករណ៍ដោយមានអន្តរាគមន៍ពីគោលនយោបាយមានបង្ហាញក្នុងរូបទី៨១។ ការព្យាករណ៍ដោយមានអន្តរាគមន៍ពីគោលនយោបាយត្រូវបានប្រើប្រាស់ជាមូលដ្ឋាននៃសេណារីយ៉ូសំរាប់ផែនការមេនេះ។




ប្រភព: ក្រុមសិក្សា JICA

**រូបទី ៨០ : ចំនួនអ្នកទេសចរក្នុងខេត្តសៀមរាបពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០២០**
**(ការព្យាករណ៍តាមនិន្នាការ និងការព្យាករណ៍ដោយមាន អន្តរាគមន៍ពីគោលនយោបាយ)**

ចំនួនអ្នកទេសចរដែលបានព្យាករណ៍សំរាប់រយៈពេលពីឆ្នាំ២០០៥ ដល់ ឆ្នាំ២០១០ គឺជានិន្នាការកំណើនតាមការ-ព្យាករណ៍តាមនិន្នាការ និងការព្យាករណ៍ដោយមានអន្តរាគមន៍ពីគោលនយោបាយ។ បន្ទាប់ពីឆ្នាំ២០១០ ដោយផ្អែកលើការព្យាករណ៍តាមនិន្នាការ ចំនួនអ្នកទេសចរបរទេសនឹងបន្តកើនឡើងក្នុងអត្រាកំណើនពី ៨%-១០% និងឡើងរហូតដល់ ៣.៣៨២.៨៦៨ នាក់នៅឆ្នាំ២០២០។ ចំណែកនៃចំនួនទេសចរបរទេសសំរាប់ការព្យាករណ៍ដោយមានអន្តរាគមន៍ពីគោលនយោបាយនឹងកើនឡើងក្នុងកំរិតកំណើនប្រចាំឆ្នាំពីចំនួន ៤-២ % នឹងកើនឡើងរហូតដល់ ២.០០៧.០២២នាក់នៅឆ្នាំ២០២០។ នៅឆ្នាំ ២០២០ ចំនួនអ្នកទេសចរបរទេសសរុបផ្អែកលើការព្យាករណ៍តាមនិន្នាការ គឺមាន ៤.៣៣០.៧០៧ នាក់ និងការព្យាករណ៍ដោយមានអន្តរាគមន៍គោលនយោបាយគឺមាន២.៨០១.៨៩៦ នាក់។

### ១១.៣.២ ចំនួន និងទីកន្លែងសំរាប់ស្នាក់នៅ

#### ១. ចំនួនទីកន្លែងសំរាប់ស្នាក់នៅ

យោងតាមចំនួននៃដំណើរមកដល់របស់អ្នកទេសចរ ក្រុមសិក្សាក៏បានព្យាករណ៍ចំនួនចាំបាច់នៃកន្លែងស្នាក់នៅដោយយោងទៅតាមសេណារីយូ**ផែនការមេ**។ យោងតាមសេណារីយូនេះ តំរូវការនៃចំនួនបន្ទប់ស្នាក់នៅត្រូវកំណត់ ដើម្បីទទួលភ្ញៀវទេសចរទាំងអស់ក្នុងរដូវដែលមានអ្នកទេសចរច្រើនបំផុត ។

តំរូវការបន្ទប់សណ្ឋាគារ និងផ្ទះសំណាក់សំរាប់ការព្យាករណ៍តាមនិន្នាការដោយមានអន្តរាគមន៍ពីគោលនយោបាយមានបង្ហាញនៅក្នុងរូបទី៨២។ នៅឆ្នាំ ២០០៧ ចំនួននៃបន្ទប់ (ដោយរួមបញ្ចូលទាំងផែនការរហូតដល់ឆ្នាំ ២០០៧)ហួសពីកំរិតតំរូវបច្ចុប្បន្ន។ យោងតាមការព្យាករណ៍តាមនិន្នាការនេះ បន្ទប់សណ្ឋាគារ និងផ្ទះសំណាក់បច្ចុប្បន្នអាចឆ្លើយតបនឹងតំរូវការរហូតដល់ឆ្នាំ២០១១។ តំរូវការបន្ទប់បន្ថែម បន្ទាប់ពីឆ្នាំ២០១៤។ រហូតដល់ឆ្នាំ២០២០ សៀមរាបអង្គរនឹងត្រូវការបន្ទប់សណ្ឋាគារ ១២.០៥៥ បន្ទប់ តាមការព្យាករណ៍ ដោយមានអន្តរាគមន៍ពីគោលនយោបាយ ។




ប្រភព : ក្រុមសិក្សា JICA

រូបទី ៨១ : តំរូវការបន្ទប់សណ្ឋាគារ និងផ្ទះសំណាក់ផ្អែកតាមការព្យាករណ៍ដោយមានអន្តរាគមន៍ពី គោលនយោបាយ ២០០៥-២០២០

## ២. ទីតាំងនៃទីកន្លែងសំរាប់ស្នាក់នៅ

សណ្ឋាគារ និងផ្ទះសំណាក់នាពេលបច្ចុប្បន្នគឺច្រើនស្ថិតក្នុងតំបន់ទីប្រជុំជន ពោលគឺនៅចន្លោះរវាងផ្សារចាស់នៅភាគខាងត្បូង និង *Le Meridien* នៅភាគខាងជើង និងតំបន់តាមបណ្តោយផ្លូវជាតិលេខ ៦។ របាយផ្ទះសំណាក់ និងសណ្ឋាគារនៅពេលអនាគតនឹងមាននិន្នាការដូចបច្ចុប្បន្នដែរ លើកលែងតែតំបន់ទេសចរណ៍ និងវប្បធម៌។

តំបន់ទេសចរណ៍ និងវប្បធម៌ ដែលគេហៅថាតំបន់សណ្ឋាគារនឹងគ្របដណ្តប់ភាគច្រើនលើដីភូមិទ្រាន ក្នុងឃុំស្លក្រាម ដែលស្ថិតនៅឭសាននៃក្រុងសៀមរាប។ តំបន់នេះគ្របដណ្តប់លើផ្ទៃដីសរុប១.០០៧ ហិចតា ដែលក្នុងនោះអាជ្ញាធរអប្សរាមិនទទួលកម្មសិទ្ធិលើដីទាំងអស់ឡើយ។ តំបន់នេះត្រូវបានចាត់ទុកថាជាតំបន់មានដង់ស៊ីតេទាប និងមានសណ្ឋាគារធំៗដែលមានផ្ទៃដីទូលំទូលាយ។ ការធ្វើផែនការសណ្ឋាគារកំពុងដំណើរការដោយតំរូវឱ្យមានចំនួនបន្ទប់ច្រើនបំផុត៤០ បន្ទប់ក្នុងមួយហិចតា។ វិនិយោគិនសណ្ឋាគារមួយចំនួនបានរៀបចំកែសំរួលសណ្ឋាគាររបស់គេឡើងវិញ។ម្យ៉ាងទៀត សារមន្ទីរមួយចំនួន និងគំរោងបង្កើតតំបន់កំសាន្តសំរាប់ទេសចរកំពុងដំណើរការ។ តំបន់នេះនឹងក្លាយជាកន្លែងសណ្ឋាគារប្រណិតតំលៃខ្ពស់នៅពេលអនាគត។ តំបន់សណ្ឋាគារនេះត្រូវបានព្យាករណ៍ថានឹងមាន ២០០០ បន្ទប់សំរាប់ភ្ញៀវនៅឆ្នាំ ២០២០។

តារាងខាងក្រោមគឺជាព័ត៌មានសង្ខេបនៃរបាយសណ្ឋាគារតាមតំបន់ក្នុងឆ្នាំ ២០០៤ ឆ្នាំ ២០១២ និងឆ្នាំ ២០២០។

**តារាង ៤១ : ចំនួន និងទីតាំងសណ្ឋាគារ និងផ្ទះសំណាក់ក្នុងស្រុកសៀមរាប**

| ឃុំ | ឈ្មោះភូមិ | ទំហំ (ហ.ត) | ចំនួនបន្ទប់សណ្ឋាគារ | | | ចំនួនបន្ទប់ផ្ទះសំណាក់ | | |
|---|---|---|---|---|---|---|---|---|
| | | | 2004 | 2012 | 2020 | 2004 | 2012 | 2020 |
| ស្លក្រាម | ស្លក្រាម | 13,6 | 100 | 100 | 100 | 123 | 123 | 123 |
| | បឹងដូនប៉ា | 90,6 | 0 | 0 | 0 | 0 | 150 | 150 |
| | ចុងកៅស៊ូ | 427,5 | 0 | 0 | 0 | 0 | 0 | 0 |
| | ដក់ពរ | 176,8 | 0 | 0 | 0 | 29 | 29 | 29 |
| | បន្ទាយចាស់ | 29,7 | 143 | 400 | 500 | 50 | 150 | 150 |
| | ត្រាង | 489,2 | 223 | 1.700 | 2.511 | 8 | 140 | 150 |
| | មណ្ឌលពីរ | 73,0 | 878 | 1.150 | 1.200 | 31 | 31 | 31 |
| | សរុប | 1300,5 | 1.344 | 3.350 | 4.311 | 241 | 623 | 633 |
| ស្វាយដង្គំ | ភូជ័យ | 137,2 | 0 | 0 | 0 | 0 | 0 | 0 |
| | តាំងព្រាក | 160,7 | 0 | 0 | 0 | 0 | 0 | 0 |
| | គោកក្រសាំង | 2442,1 | 0 | 0 | 0 | 0 | 0 | 0 |
| | ស្វាយព្រៃ | 90,0 | 0 | 0 | 0 | 0 | 0 | 0 |
| | រកាបុស | 156,2 | 0 | 0 | 0 | 0 | 0 | 0 |
| | ថ្មី | 135,8 | 0 | 0 | 0 | 0 | 0 | 0 |
| | ស្វាយដង្គំ | 223,3 | 239 | 270 | 350 | 215 | 429 | 450 |
| | សាលាកំរើក | 164,2 | 738 | 1.000 | 1.050 | 40 | 50 | 50 |
| | ក្រួស | 154,4 | 209 | 209 | 209 | 13 | 13 | 13 |
| | វិហារចិន | 65,9 | 72 | 72 | 72 | 106 | 106 | 106 |
| | ស្ទឹងថ្មី | 132,8 | 100 | 337 | 450 | 227 | 227 | 227 |
| | មណ្ឌលមួយ | 18,1 | 240 | 300 | 340 | 38 | 38 | 38 |
| | មណ្ឌលបី | 35,8 | 835 | 1.150 | 1.200 | 238 | 238 | 238 |
| | តាផុល | 114,6 | 1.145 | 1.670 | 1.850 | 138 | 138 | 138 |
| | សរុប | 685,8 | 3.578 | 5.008 | 5.521 | 1.015 | 1.239 | 1.260 |
| គោកចក | ក្រពាងលេះ | 241,6 | 0 | 0 | 0 | 8 | 8 | 8 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | វាល | 865,1 | 0 | 0 | 0 | 0 | 0 | 0 |
| | ទៀនត្បូង | 142,4 | 0 | 0 | 0 | 0 | 0 | 0 |
| | ចោកចាន់ | 445,5 | 0 | 0 | 0 | 0 | 0 | 0 |
| | ខ្វៀន | 142,3 | 0 | 0 | 0 | 0 | 0 | 0 |
| | គោបេង | 696,7 | 0 | 0 | 0 | 0 | 0 | 0 |
| | គោកត្នោត | 698,2 | 0 | 0 | 0 | 0 | 0 | 0 |
| | ទទឹងក្រៅ | 579,6 | 0 | 0 | 0 | 0 | 0 | 0 |
| | សរុប | 3811,3 | 0 | 0 | 0 | 8 | 8 | 8 |
| សាលាកំរើក | វត្តពោធិ | 253,0 | 620 | 1.000 | 1.300 | 511 | 950 | 1.000 |
| | វត្តស្វាយ | 148,8 | 0 | 0 | 0 | 0 | 0 | 0 |
| | វត្តដំណាក់ | 112,2 | 0 | 200 | 300 | 24 | 50 | 50 |
| | សាលាកំរើក | 61,2 | 18 | 18 | 18 | 0 | 0 | 0 |
| | បន្ទុង | 58,0 | 0 | 0 | 0 | 0 | 0 | 0 |
| | តាវាង | 117,5 | 24 | 24 | 50 | 38 | 130 | 149 |
| | ត្រពាំងទ្រើង | 90,0 | 0 | 0 | 0 | 0 | 0 | 0 |
| | សរុប | 840,6 | 662 | 1.242 | 1.668 | 573 | 1.130 | 1.199 |
| នគរធំ | ភូមិទាំងអស់ | 5488,2 | 0 | 0 | 0 | 0 | 0 | 0 |
| ជ្រាវ | ភូមិទាំងអស់ | 6580,2 | 0 | 0 | 0 | 0 | 0 | 0 |
| ចុងឃ្នាស | ភូមិទាំងអស់ | N,A, | 0 | 0 | 0 | 0 | 0 | 0 |
| សម្បូរ | ភូមិទាំងអស់ | 2697,0 | 0 | 0 | 0 | 0 | 0 | 0 |
| សៀមរាប | ភូមិទាំងអស់ | 5515,3 | 0 | 0 | 0 | 0 | 0 | 0 |
| ស្រង៉ែ | កសិកម្ម | 110,7 | 601 | 700 | 800 | 0 | 0 | 0 |
| | ថ្កល | 150,3 | 0 | 200 | 200 | 0 | 0 | 0 |
| | រកាធំ | 141,7 | 0 | 0 | 0 | 0 | 0 | 0 |
| | ព្រៃធំ | 96,5 | 0 | 0 | 0 | 0 | 0 | 0 |
| | ស្រង៉ែ | 89,0 | 0 | 0 | 0 | 0 | 0 | 0 |
| | បន្ទុង | 84,6 | 0 | 0 | 0 | 0 | 0 | 0 |
| | តាចាក | 3065,4 | 0 | 0 | 0 | 0 | 0 | 0 |
| | សរុប | 3738,3 | 601 | 900 | 1,000 | 0 | 0 | 0 |
| សរុបរួម | | 10376,5 | 6.185 | 10.500 | 12.500 | 1.837 | 3.000 | 3.100 |

ប្រភព : ក្រុមសិក្សា

កំណត់សំគាល់

- តួលេខដែលមានស្រមោលបង្ហាញពីតំបន់ក្រុងនៅពេលអនាគត។
- * ឃុំទ្រាំងស្ថិតក្នុងតំបន់សណ្ឋាគារអប្សរា។

## ១២. អនុសាសន៍

១. រហូតមកដល់ពេលនេះ សៀមរាបបានឆ្លងកាត់ទេសចរណ៍បែបគំហុក ។ ទេសចរណ៍បែបគំហុកនេះបានកើតមានឡើងនៅតាមតំបន់ទេសចរណ៍ និងសកម្មភាពកំសាន្តតិចតួចប៉ុណ្ណោះក្រៅពីបរិវេណអង្គរ ។ សេវាកម្មសាធារណៈសំខាន់ៗមិនអាចឆ្លើយតបទៅនឹងការអភិវឌ្ឍន៍សណ្ឋាគារយ៉ាងឆាប់រហ័យ ។ គេយល់ឃើញថា ក្រុងសៀមរាបពុំទាន់មានសុវត្ថិភាព ស្អាត ឬមានភាពងាយស្រួលសំរាប់ឱ្យភ្ញៀវទេសចរបុគ្គល ឬគ្រួសារដើម្បីដើរកំសាន្តនៅឡើយ ។ អ្នកបង្កើតគោលនយោបាយគួរយល់ថា ការអភិវឌ្ឍន៍ទេសចរណ៍ និងក្រុងដូចនេះមិនអាចមាននិរន្តរភាពឡើយនៅពេលអនាគត ។ គេគួរតែកែប្រែពីទេសចរណ៍បែបបរិមាណទៅជាទេសចរណ៍គុណភាព និងគួរតែធ្វើឡើងឱ្យស្របទៅនឹងលក្ខខណ្ឌបរិស្ថានធម្មជាតិ ។ រដ្ឋាភិបាលគួរតែយកចិត្តទុកដាក់ខ្ពស់ក្នុងការកំណត់ឱ្យបានច្បាស់លាស់នូវបញ្ហាក្រុង និងបរិស្ថានក្នុងសៀមរាប ។ ម្យ៉ាងវិញទៀត ការធ្លាក់ចុះខាងបរិស្ថាន និងការខូចខាតដែលអាចកើតមានដល់ក្រុងអាចធ្វើឱ្យភ្ញៀវទេសចរចេញពីសៀមរាប នៅពេលមានការប្រកួតប្រជែងកើនខ្ពស់ពីតំបន់ទេសចរណ៍ផ្សេងៗទៀតនៅលើពិភពលោក ។

២. កត្តាដ៏សំខាន់បំផុតមួយគឺទឹកសំរាប់ភ្ញៀវទេសចរ ប្រជាជនមូលដ្ឋាន និងសំរាប់ដីកសិកម្មដែលអាចប្រើជាខ្សែក្រវ៉ាត់បៃតង ។ ការបូមទឹកក្រោមដីរបស់បុគ្គលសំរាប់បំរើគោលបំណងពាណិជ្ជកម្មគួរចុះបញ្ជី ត្រួតពិនិត្យ និងបង់ប្រាក់ នៅពេលចាំបាច់ ។ នៅពេលបច្ចុប្បន្ន ការងារនេះអាចអនុវត្តបាន បន្ទាប់ពីមានប្រព័ន្ធគ្រប់គ្រងទឹកស្អាតក្នុងក្រុង ។ គួររៀបចំផែនការសំរាប់ខេត្តទាំងមូលឱ្យបានលឿនបំផុត បើអាចធ្វើបានដើម្បីគ្រប់គ្រងធនធានទឹកដែលមានស្រាប់ និងដែលមានសក្តានុពល និងសំរបសំរួលឱ្យមានការប្រើប្រាស់ទឹករយៈពេលយូរអង្វែង ។

៣. ការគ្រប់គ្រងលើការប្រើប្រាស់ដីគឺជាផ្នែកដ៏សំខាន់មួយទៀត ។ ការអភិវឌ្ឍន៍ក្រុងគួរតែអនុវត្តតែនៅក្នុងតំបន់ពង្រីកក្រុងដែលបានស្នើឡើង ។ អាស្រ័យហេតុនេះ ត្រូវផ្តល់ហេដ្ឋារចនាសម្ព័ន្ធក្រុងឱ្យបានគ្រប់គ្រាន់ ។ គេអាចការពារតំបន់ប្រវត្តិសាស្ត្រ និងដីកសិកម្មពីការពង្រីកក្រុងដោយគ្មានការត្រួតពិនិត្យត្រឹមត្រូវ ។ នៅពេលមានការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទាន់ពេលវេលា គេអាចបញ្ចៀសដីសាធារណៈពីការសាងសង់ ការតាំងទីលំនៅ និងការកាន់កាប់ដីខុសច្បាប់ដោយមានការចូលរួមពេញលេញពីប្រជាជនងាយរងគ្រោះក្នុងសង្គម ។ ការបង្កើតរចនាសម្ព័ន្ធរដ្ឋបាលបែបស្មុគស្មាញនាពេលបច្ចុប្បន្នសំរាប់ការធ្វើផែនការប្រើ ប្រាស់ដីធ្លីគួរតែសំរួលដើម្បីឱ្យការគ្រប់គ្រងដីធ្លីមានប្រសិទ្ធភាព ។

៤. ផែនការមេរយៈពេលវែងនេះគឺជាឯកសារមានជីវិត ។ ឯកសារនេះគួរតែពិនិត្យកែលំអដើម្បីឱ្យឆ្លើយតបទៅនឹងកាលៈទេសៈប្រែប្រួល ជាពិសេសដោយខេត្តសៀមរាប អាជ្ញាធរអប្សរា គណៈកម្មការអភិវឌ្ឍន៍កម្ពុជា និងការិយាល័យនៃទីស្តីការរដ្ឋមន្ត្រី ។ គំរោងអាទិភាពដែលបានស្នើឡើងគួរធ្វើការពិនិត្យឱ្យបានល្អិតល្អន់ដើម្បីធ្វើការរៀបចំ និងអនុវត្តឱ្យទាន់ពេលវេលា ។ ផ្គួបផ្សំជាមួយនឹងកិច្ចខិតខំទាំងនេះ អាជ្ញាធរខេត្តគួរពង្រឹងមុខងាររបស់ខ្លួនដើម្បីពិនិត្យតាមដានការវិនិយោគ ការប្រើប្រាស់ដី គំរោងបរិស្ថានរបស់រដ្ឋាភិបាល និងពិនិត្យកែប្រែផែនការមេនេះ ។

៥. គំរោងសាកល្បង ដែលមានឈ្មោះ " ការធ្វើឱ្យសៀមរាបកាន់តែស្រស់ស្អាតឡើង" និង "ការតាំងពិព័រណ៍ផលិតផលអង្គរ ឆ្នាំ២០០៥" បានទទួលជោគជ័យ ដោយសារគំនិតផ្តួចផ្តើមដ៏រឹងមាំរបស់មូលដ្ឋាន និងការគាំទ្រពីថ្នាក់ជាតិយ៉ាងទូលំទូលាយ ។ គំរោងទាំងនោះគួរចាត់ទុកជាគំរោងគំរូសំរាប់បន្តសកម្មភាពលើកកំពស់បរិស្ថានក្រុង និង

ពង្រីកឱ្យបានច្រើននូវផលប្រយោជន៍សេដ្ឋកិច្ចនៅមូលដ្ឋាន និងសោភ័ណភាពនៅជនបទ។ គំនិតផ្តួចផ្តើមនៅមូលដ្ឋានដែលអនុវត្តដោយអភិបាលខេត្តគួរតែទទួលបានការជ្រោមជ្រែងជាបន្តពីក្រសួងពាក់ព័ន្ធ ផ្នែកឯកជន និងប្រជាជននៅមូលដ្ឋាន។

៦. ការកសាងសមត្ថភាពនៃអាជ្ញាធរនៅថ្នាក់មូលដ្ឋាន ជាពិសេសអាជ្ញាធរខេត្តគឺជាផ្នែកដ៏សំខាន់សំរាប់ការអភិវឌ្ឍន៍សៀមរាបប្រកបដោយនិរន្តរភាព។អាជ្ញាធរខេត្តគួរពង្រឹងមន្ត្រីធ្វើផែនការរបស់ខ្លួនជាបន្ទាន់នូវជំនាញបច្ចេកទេស។ ខេត្តគួរលើកកំពស់ការចែករំលែកព័ត៌មានអំពីការអភិវឌ្ឍន៍រវាងមន្ទីរ និងអាជ្ញាធរផ្សេងៗនៅថ្នាក់ខេត្តតាមរយៈការបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ខេត្ត។ ជាលទ្ធផល ខេត្តនឹងអាចក្លាយជាស្ថាប័នមួយដូចជាក្រុមប្រឹក្សាអភិវឌ្ឍន៍ខេត្ត ឬគណៈកម្មការគ្រប់គ្រងខេត្ត។ ខេត្តគួរមានកញ្ចប់ថវិកា ជាពិសេសសំរាប់ថែទាំសេវាកម្មសាធារណៈជាយុទ្ធសាស្ត្រផ្សេងៗ ដូចជា ផ្លូវថ្នល់ ការប្រមូលសំណល់ និងប្រព័ន្ធបង្ហូរទឹកភ្លៀង។ ប្រភពហិរញ្ញវត្ថុដែលអាចទទួលបាន និងមានចំនួនច្រើនគឺបានមកពីចំណែកនៃថវិកាចូលទស្សនារមណីយដ្ឋានអង្គរ។

៧. ខុសពីខេត្តផ្សេងៗទៀតក្នុងប្រទេសកម្ពុជា ខេត្តសៀមរាបពឹងផ្អែកយ៉ាងខ្លាំងទៅលើវិស័យទេសចរណ៍ និងក្រុង។ ដូចនេះ អាជ្ញាធរខេត្តសៀមរាបគួរពង្រឹងអំណាចក្នុងការធ្វើសេចក្តីសំរេចចិត្ត និងសមត្ថភាពបច្ចេកទេសសំរាប់ធ្វើផែនការត្រួតពិនិត្យ និងថែរក្សាបរិស្ថានក្រុង។ អំណាចក្នុងការធ្វើសេចក្តីសំរេចរបស់ខេត្ត និងសមត្ថភាពបច្ចេកទេសគួរតែមានប្រសិទ្ធភាពដោយមានការគាំទ្រខាងបច្ចេកទេស និងច្បាប់ពីក្រសួង និងមន្ទីរពាក់ព័ន្ធ ព្រមទាំងមានការគាំទ្រពីអាជ្ញាធរអប្សរា។

៨. រមណីយដ្ឋានអង្គរគឺជានិមិត្តរូបនៃអត្តសញ្ញាណជាតិ ជាបេតិកភណ្ឌវប្បធម៌ពិភពលោក និងជាប្រភពដ៏សំខាន់នៃរូបិយវត្ថុបរទេស។ ដូចនេះ សៀមរាបគួរតែជាក្រុងគំរូលើការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពក្នុងប្រទេសកម្ពុជា។ សៀមរាមមិនត្រឹមតែមានការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពប៉ុណ្ណោះទេ តែថែមទាំងធ្វើការឆ្លុះបញ្ចាំងពីគតិបណ្ឌិតសម័យអង្គរលើការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ឆ្លុះបញ្ចាំងពីវប្បធម៌សម្បូរបែប និងការចូលរួមរបស់ប្រជាជន ក្នុងសកម្មភាពអភិវឌ្ឍន៍ក្នុងសតវត្សទី២១។ សៀមរាបមិនត្រឹមតែជាទីតាំងនៃរមណីយដ្ឋានរូបវន្តប៉ុណ្ណោះទេ តែថែមទាំងជាប្រភពព្រលឹងសកលដែលកំពុងត្រូវសាយភាយទៅកាន់កន្លែងផ្សេងៗទៀតក្នុងពិភពលោក។ សៀមរាបក៏ជាកន្លែងទាក់ទាញខាងវប្បធម៌យ៉ាងខ្លាំងនៅតំបន់អាស៊ីអាគ្នេយ៍។ ដើម្បីធ្វើឱ្យសំរេចនូវគំនិតទាំងនេះគ្រប់ក្រសួង អាជ្ញាធរ និងក្រុមប្រឹក្សានៃរដ្ឋាភិបាលថ្នាក់ជាតិគួរចែករំលែកការយល់ដឹងរួម ដែលជាកត្តាសំខាន់ សំរាប់ជួយសៀមរាបទាំងហិរញ្ញវត្ថុ និងបច្ចេកទេស ជាពិសេសលើការកែលំអបរិស្ថាន និងក្រុង។

## ឧបសម្ព័ន្ធ ៖ សេចក្តីសង្ខេបគំរោង និងកម្មវិធីអាទិភាព

## JICA- ការសិក្សាអំពីផែនការមេរួមសំរាប់ការអភិវឌ្ឍទីក្រុងសៀមរាប/អង្គរប្រកបដោយនិរន្តរភាព

### សេចក្ដីសង្ខេបគំរោង

### វិស័យ : ការអភិវឌ្ឍទីក្រុង

| លេខកូដ | ឈ្មោះគំរោង | អ្នកទទួលផល ឬក្រុមគោលដៅ | ថវិកាដែលបានសន្មត | តំលៃប៉ាន់ស្មាន | អាទិភាពគំរោង |
|---|---|---|---|---|---|
| U-1 | គំរោងអភិវឌ្ឍន៍តំបន់មណ្ឌលក្រុង | ប្រជាជនក្នុងក្រុងសៀមរាប ( ប្រមាណ ៩០.០០០)និងភ្ញៀវ) | ជំនួយបរទេស | ៧.៦០០ ( ០០០ដុល្លារ) | អាទិភាព |

| ទីតាំងគំរោង | ទីភ្នាក់ងារអនុវត្ត | មន្ទីរ | អ្នកទទួលទំនាក់ទំនង | ទូរស័ព្ទ | អ៊ីម៉ែល |
|---|---|---|---|---|---|
| ក្នុង និងជុំវិញមណ្ឌលក្រុងសៀមរាប | ខេត្តសៀមរាប | អភិបាលខេត្តរង | លោក ឃី ប៊ុនធឿន | | |

**ប្រវត្តិ :**

តំបន់មណ្ឌលក្រុងគឺជាមជ្ឈមណ្ឌលរដ្ឋបាល ពាណិជ្ជកម្ម និងទេសចរណ៍ខេត្តសៀមរាប ។ ហេដ្ឋារចនាសម្ព័ន្ធគ្រឹះនៃមណ្ឌលក្រុង ដូចជាបណ្ដាញផ្លូវត្រូវបានកសាងឡើងនៅសម័យក្រោមអាណានិគមបារាំងក្នុងទសវត្សរ៍ឆ្នាំ ១៩៣០ ។ នៅជុំវិញមជ្ឈមណ្ឌលក្រុងគឺជាតំបន់ពង្រីកក្រុងដែលមានហេដ្ឋារចនាសម្ព័ន្ធពុំសមស្របទៅនឹងលក្ខណៈបច្ចេកទេសឡើយ ។ ប្រសិនបើគ្មានការចាត់វិធានការប្រកបដោយប្រសិទ្ធភាពទេនោះ តំបន់ក្រុងទាំងមូលនឹងប្រឈមមុខទៅនឹងការធ្លាក់ចុះនៃបរិស្ថានក្រុង ដោយសារការបំពុល ការកកស្ទះ និងការពង្រីកលំនៅដ្ឋាន ដែលគ្មានផែនការច្បាស់លាស់ ។

**គោលបំណងគំរោង :**

គំរោងនេះមានគោលបំណងបំពេញតំរូវការហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដែលមានអាទិភាពខ្ពស់ ដោយផ្អែកលើចក្ខុវិស័យ និងក្របខ័ណ្ឌដែលបានបង្កើតឡើងក្នុងពេលកំពុងសិក្សា ។ គំរោងនេះគឺជាគំរោងលើកកំពស់តំបន់ក្រុងដែលគ្រប់គ្រងដោយអាជ្ញាធរខេត្ត និងមានការចូលរួមពីមន្ទីរពាក់ព័ន្ធ ។ ការសិក្សានេះបានស្នើឡើងដោយបង្កើតគណៈកម្មការជំនាញអភិវឌ្ឍទីក្រុងសៀមរាប និងគណៈកម្មការនេះ គឺជាផ្នែកមួយរបស់រូបលើការងារលើកកំពស់ក្រុងនៅត្រូវបិសិយ ។

**ទំរង់រូប/ផ្នែករបស់គំរោង និងកម្មវិធី :**

១. កែលំអផ្លូវដើរ : ប្រមាណជា ៣ គីឡូម៉ែត្រ (វិថីស៊ីវុត្ថា និងវិថីជ័យក្នុងតំបន់ចំណាស់)
២. ដាំដើមឈើជាជួរនៅតំបន់ផ្សារចាស់ : ប្រមាណជា ២ គ.ម (វិថីស៊ីវុត្ថា និងផ្លូវក្នុងតំបន់ផ្សារចាស់)
៣. កែលំអភ្លើងតាមផ្លូវ : និងកំណត់នៅពេលក្រោយ ( ភាគច្រើននៅតាមដងស្ទឹងសៀមរាប)
៤. បង្កើតឧទ្យានក្នុងក្រុង
៥. អភិវឌ្ឍឡើងវិញតំបន់មន្ទីរពេទ្យខេត្ត
៦. អភិវឌ្ឍឡើងវិញតំបន់ទីប្រជុំជនក្នុងមណ្ឌលក្រុង
៧. កែលំអផ្លូវដើរក្នុងក្រុង : ប្រមាណជា ១០.៥ គ.ម ( ភាគច្រើនក្នុងតំបន់ពង្រីកក្រុង)
៨. សាងសង់ផ្លូវថ្មី : ប្រហែល ១,១ គ.ម ( សំរាប់ព្រំប្រទល់ខាងកើត និងខាងត្បូងតំបន់ពង្រីកក្រុង)

**លទ្ធផលគំរោង :**

លទ្ធផលផ្ទាល់របស់គំរោងគឺការបង្កើតបរិស្ថានក្រុងសមរម្យ ស្អាត និងជាទីទាក់ទាញក្នុងតំបន់គោលដៅ ។ លទ្ធផលប្រយោលគឺការបង្កើតប្រព័ន្ធសំរបសំរួល ថ្នាក់មន្ទីរក្រោមការដឹកនាំរបស់ខេត្ត និងការកសាងសមត្ថភាព ដែលជាតំរូវការចាំបាច់សំរាប់បន្តអនុវត្តគំរោងស្រដៀងគ្នានេះទៅទីកន្លែងផ្សេងៗទៀត

**ផលប៉ះពាល់បរិស្ថាន និងសង្គម :**

គំរោងនឹងជ្រើសរើសតំរូវការហេដ្ឋារចនាសម្ព័ន្ធ ដែលនឹងបង្កផលប៉ះពាល់តិចតួចដល់សង្គម និងបរិស្ថាន ។

**គំរោងពាក់ព័ន្ធ :**

គំរោងបណ្ដាញផ្លូវតភ្ជាប់ ដំណាក់ ១ (TR-2)

**កាលវិភាគអនុវត្ត :**

| | |
|---|---|
| ១. ការវិនិច្ឆ័យ | មីនា ០៦ - ធ្នូ ០៦ |
| ២. សិក្សាតាមទីកន្លែង និង D/D | មីនា ០៦ - ធ្នូ ០៦ |
| ៣. រៀបចំថ្លៃលំអិត | មីនា ០៦ - មិថុនា ០៧ |
| ៤. ដេញថ្លៃ និងផ្ដល់កិច្ចសន្យា | កក្កដា ០៧ - ធ្នូ ០៧ |
| ៥. ការកសាងសមត្ថភាពសំរាប់ប្រតិបត្តិ និងគ្រប់គ្រង | ឧសភា ០៨-វិច្ឆិកា ០៨ |

**ការចំណាយសំរាប់គំរោង ( ០០០ ដុល្លារ) :**

| | |
|---|---|
| ១. ចំណាយផ្ទាល់ | ១.៨៦២ |
| ២. ការកសាងសមត្ថភាព | ៣០០ |
| ៣. ប្រាក់បំរុងប្រវិត្ត | ១៨៦ |
| ៤. ការបង្កើនតំលៃ | ២០៥ |
| ៥. សេវាកម្មវិស្វកម្ម | ១៨៦ |
| ៦. ការវិនិយោគ | ៤.៨៦៤ |
| សរុប | ៧.៦០៤ |

## JICA - ការសិក្សាអំពីផែនការមេរួមសំរាប់ការអភិវឌ្ឍន៍ក្រុងសៀមរាប/អង្គរប្រកបដោយចីរភាព

### សេចក្ដីសង្ខេបគំរោង

### វិស័យ : ការអភិវឌ្ឍន៍ក្រុង

| ល.កូដ | ឈ្មោះគំរោង | អ្នកទទួលផល ឬក្រុមគោលដៅ | ថវិកាដែលបានសន្មត | តំលៃប៉ាន់ស្មាន | អាទិភាពគំរោង |
|---|---|---|---|---|---|
| U-2 | គំរោងកសាងសមត្ថភាពធ្វើផែនការក្រុង | ប្រជាជនក្នុងក្រុងសៀមរាប ( ប្រមាណ ៩០.០០០ ) និងភ្ញៀវ | ជំនួយបរទេស | នឹងបញ្ជាក់នៅពេលក្រោយ | អាទិភាព |

| ទីតាំងគំរោង | ទីភ្នាក់ងារអនុវត្ត | មន្ទីរ | អ្នកទទួលទំនាក់ទំនង | ទូរស័ព្ទ | អ៊ីម៉ែល |
|---|---|---|---|---|---|
| តំបន់ក្រុងនៃខេត្តសៀមរាប ( មើលផែនទី ) | ខេត្តសៀមរាប | អភិបាលខេត្តរង | លោក លី ប៊ុនធឿន | | |

**ប្រវត្តិ :**

ទោះបីកម្ពុជាមានច្បាប់ និងបទដ្ឋានច្បាប់សំរាប់ធ្វើផែនការក្រុងក៏ដោយ ក៏ការពង្រឹងច្បាប់ និងបទដ្ឋានច្បាប់ទាំងនោះនៅមានកំរិតនៅឡើយ ដោយសារកង្វះខាតបទពិសោធន៍ និងទំនុកចិត្ត ។ គំរោងនេះមានគោលបំណងជួយអាជ្ញាធរមូលដ្ឋានដើម្បីពង្រឹងសមត្ថភាព ពង្រឹងចក្ខុវិស័យសំរាប់ធ្វើផែនការក្រុងប្រកបដោយចីរភាព និងផែនការប្រើប្រាស់ដីធ្លី ។

**គោលបំណងគំរោង :**

គំរោងនេះមានគោលបំណងពង្រឹងសមត្ថភាពសំរាប់គ្រប់គ្រង ធ្វើផែនការក្រុង និងការប្រើប្រាស់ GIS សំរាប់ជំនាញធ្វើផែនការ ។ ជំនាញការបរទេសនឹងត្រូវផ្ទេរបច្ចេកទេសប្រចាំថ្ងៃដល់មន្ត្រីក្នុងស្រុកសំរាប់ការគ្រប់គ្រងក្រុង និងធ្វើផែនការក្រុងដោយផ្អែកលើគំរូនៃការរីកលំអក្រុងនៅតាមវិស័យផ្សេងៗ ស្របទៅនឹងគំរោង U-1 ។

**ទំរង់រូប/ផ្នែករបស់គំរោង និងកម្មវិធី :**

១. ជំនាញការសំរាប់ធ្វើផែនការក្រុង ( ប្រធានក្រុម )
២. ជំនាញការសំរាប់រដ្ឋបាលមូលដ្ឋាន
៣. ជំនាញការសំរាប់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន
៤. ជំនាញការសំរាប់ GIS

**លទ្ធផលគំរោង :**

លទ្ធផលផ្ទាល់របស់គំរោងគឺការលើកកំពស់សមត្ថភាពសំរាប់ការគ្រប់គ្រង និងការធ្វើផែនការក្រុងឱ្យកាន់តែប្រសើរឡើង ។

**ផលប៉ះពាល់បរិស្ថាន និងសង្គម :**

គំរោងនេះនឹងពុំមានឥទ្ធិពលអាក្រក់ទៅលើបញ្ហាបរិស្ថាន និងសង្គមទេ ។

**គំរោងពាក់ព័ន្ធ :**

គំរោងនេះនឹងអនុវត្តទៅតាមគំរោងផែនការមេនៃក្រុងសៀមរាបអង្គរ ។

**កាលវិភាគអនុវត្ត :**

២០០៥ : សំណើ វាយតំលៃ និងរៀបចំ
២០០៦ : អនុវត្តគំរោង ជំហាន ១
២០០៧ : អនុវត្តគំរោង ជំហាន ២
២០០៨ : វាយតំលៃបន្ទាប់ពីការអនុវត្តគំរោង

**ការចំណាយសំរាប់គំរោង :**

នឹងកំណត់នៅពេលក្រោយ ។

## JICA - ការសិក្សាអំពីផែនការមេរួមសំរាប់ការអភិវឌ្ឍន៍ក្រុងសៀមរាប/អង្គរប្រកបដោយនិរន្តរភាព

### សេចក្តីសង្ខេបគំរោង

### វិស័យ : ការគ្រប់គ្រងបរិស្ថាន

| ល.កូដ | ឈ្មោះគំរោង | អ្នកទទួលផល ឬក្រុមគោលដៅ | ថវិកាដែលបានសន្មត | តំលៃប៉ាន់ស្មាន | អាទិភាពគំរោង |
|---|---|---|---|---|---|
| E-2 | ការលើកកំពស់ការយល់ដឹងបរិស្ថាន | ប្រជាជន ភ្ញៀវទេសចរ សណ្ឋាគារ និងស្ថាប័នជំនួញ | ជំនួយបរទេស | ៣៣០ (000ដុល្លារ) | អាទិភាព |

| ទីតាំងគំរោង | ភ្នាក់ងារអនុវត្ត | មន្ទីរ | អ្នកទទួលទំនាក់ទំនង | ទូរស័ព្ទ | អ៊ីម៉ែល |
|---|---|---|---|---|---|
| ស្រុកសៀមរាប | មន្ទីរបរិស្ថានខេត្ត | | | | |

**ប្រវត្តិ :**

ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងកំណើនប្រជាជនកំពុងធ្វើឱ្យប៉ះពាល់ដល់បរិស្ថានយ៉ាងឆាប់រហ័ស ទាំងបរិស្ថានធម្មជាតិ និងបរិយាកាសរស់នៅរបស់ប្រជាជន និងភ្ញៀវនៅសៀមរាប ។ សំណល់រឹង សំណល់រាវ និងតំរូវការអគ្គីសនីបានបង្កបន្ទុកធ្ងន់ធ្ងរដល់ធនធានធម្មជាតិ និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ ដូចជាតំលៃវិនិយោគសំរាប់អភិវឌ្ឍន៍រោងចក្រប្រព្រឹត្តិកម្មទឹក ជាដើម ។ វិធានការមួយក្នុងចំណោមវិធានការចាំបាច់ទាំងឡាយដើម្បីអភិវឌ្ឍប្រកបដោយនិរន្តរភាពគឺត្រូវកាត់បន្ថយតំរូវការធនធានធម្មជាតិរបស់ប្រជាជនតាមរយៈការអប់រំសាធារណជន និងសណ្ឋានអំពីទំនាក់ទំនង និងឥទ្ធិពលនៃសកម្មភាពរបស់គេលើបរិស្ថានរស់នៅ និងធនធានធម្មជាតិ ។

**គោលបំណងគំរោង :**

គោលបំណងជាក់លាក់របស់គំរោងមានដូចខាងក្រោម :

១. កាត់បន្ថយតំរូវការប្រើប្រាស់ទឹក និងអគ្គីសនី និងកាត់បន្ថយផលប៉ះពាល់លើធនធានធម្មជាតិ

២. កាត់បន្ថយការចោលបរិមាណសំណល់រាវ និងការចំណាយសរុបលើការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ

៣. កាត់បន្ថយឱ្យដល់កំរិតអប្បបរមាលើការវិនិយោគនៅពេលអនាគតរបស់អ្នកផ្គត់ផ្គង់ដោយការបង្វែរ និងកំណត់កំរិតតំរូវការ

៤. បន្តធ្វើឱ្យក្រុងមានការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព យកចិត្តទុកដាក់លើបរិស្ថាន និងមានសោភ័ណភាព

**ទំរង់រូប/ផែ្នករបស់គំរោង និងកម្មវិធី :**

១. ផ្តល់ឯកសារ និងសម្ភារៈសំរាប់ការលើកកំពស់ចំណេះដឹងបរិស្ថានដល់សាធារណជន

២. ធ្វើសិក្ខាសាលាសំរាប់ស្ថាប័នពាក់ព័ន្ធក្នុងរដ្ឋាភិបាល ដូចជា មន្ទីរបរិស្ថាន ទីភ្នាក់ងារសេវាកម្មទឹកសៀមរាប និងអគ្គីសនីកម្ពុជា

៣. លើកកំពស់ការយល់ដឹងជាសាធារណៈសំរាប់ក្រុមគោលដៅ (សាធារណជន និងសមាគមសណ្ឋាគារ)

៤. រៀបចំគោលការណ៍ណែនាំអំពីជីវិតរស់នៅ និងជំនួញដែលយកចិត្តទុកដាក់លើបរិស្ថាន

៥. ផែនការសកម្មភាពសំរាប់អនាគត

**លទ្ធផលគំរោង :**

១. ការអប់រំអំពីអនាម័យ និងបរិយាកាសរស់នៅ ២. លើកកំពស់របៀបគិតគូរបរិស្ថានទាំងបី (កាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃទឹក ថាមពល និងសំណល់រឹង)
៣. កាត់បន្ថយឱ្យដល់កំរិតអប្បបរមានូវការវិនិយោគ និងពន្ធនៅពេលអនាគត ៤. លើកកំពស់សោភ័ណភាពក្រុង និង៥. គោលការណ៍ណែនាំ

**ឥទ្ធិពលលើបរិស្ថាន និងសង្គម :**

១. និងកាត់បន្ថយការប្រើប្រាស់ទឹក និងតំលៃសំរាប់ការផ្គត់ផ្គង់ទឹក និងការធ្វើប្រព្រឹត្តិកម្មទឹក

២. និងកាត់បន្ថយបរិមាណសំណល់រាវ និងតំលៃសំរាប់ការធ្វើប្រព្រឹត្តិកម្មទឹក

៣. កាត់បន្ថយបរិមាណសំណល់រឹង ៤. កាត់បន្ថយការប្រើប្រាស់ភ្លើង ថ្លៃភ្លើង និងការចំណាយលើការវិនិយោគនៅពេលអនាគត

៥. និងកាត់បន្ថយផលប៉ះពាល់ដល់បរិស្ថាន និងធ្វើការអភិវឌ្ឍន៍កាន់តែមាននិរន្តរភាពជាងមុន

**កាលវិភាគអនុវត្ត :**

| | |
|---|---|
| ១. លទ្ធកម្ម | តុលា ០៦ |
| ២. អភិវឌ្ឍមត្ថភាព | មិថុនា ០៦ - មីនា ០៧ |
| ៣. ទំនាក់ទំនងសាធារណៈ | ២០០៧-២០១២ |

**ការចំណាយសំរាប់គំរោង (000 ដុល្លារ) :**

| | |
|---|---|
| ១. ចំណាយផ្ទាល់ | ៣០ |
| ២. ការកសាងសមត្ថភាព | ៣០០ |
| សរុប | ៣៣០ |

**គំរោងពាក់ព័ន្ធ :**

១. លើកកំពស់ការយល់ដឹងរបស់ប្រជាជនសំរាប់ធ្វើឱ្យសៀមរាបកាន់តែស្រស់ស្អាតឡើង ដូចជាគំរោងសាកល្បងដែលឧបត្ថម្ភដោយ JICA

## JICA - ការសិក្សាអំពីផែនការមេរួមសំរាប់ការអភិវឌ្ឍន៍ក្រុងសៀមរាប/អង្គរ ប្រកបដោយនិរន្តរភាព

### សេចក្តីសង្ខេបគំរោង

### វិស័យ : ការអភិវឌ្ឍន៍ទេសចរណ៍

| ល.កូដ | ឈ្មោះគំរោង | អ្នកទទួលផល ឬក្រុមគោលដៅ | ថវិកាដែលបាន | តំលៃប៉ាន់ស្មាន | អាទិភាពគំរោង |
|---|---|---|---|---|---|
| TO-1 | បណ្តាញទេសចរណ៍បេតិកភណ្ឌខ្មែរ និងគំរោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ | ប្រជាជន ភ្ញៀវទេសចរ សណ្ឋាគារ និងស្ថាប័នជុំវិញ និងវិស័យសាធារណៈ | ជំនួយបរទេស | ២៦.៥៥០ (០០០ដុល្លារ) | អាទិភាព |

| ទីតាំងគំរោង | ភ្នាក់ងារអនុវត្ត | មន្ទីរ | អ្នកទទួលខុសត្រូវ | ទូរស័ព្ទ | អ៊ីម៉ែល |
|---|---|---|---|---|---|
| តំបន់ភាគច្រើន (ខេត្ត ៨) | ក្រ. និងម.ទេសចរណ៍ អប្សរា ធនធានទឹក សាធារណការ ក្រ.វិចិត្រសិល្បៈ | | | | |

**ប្រវត្តិ :**

ប្រាសាទភាគច្រើននៅកម្ពុជាបានសាងសង់រវាងសតវត្សរ៍ទី៧ និង១៣ក្នុងខេត្តស.រ និងខេត្តជិតខាង ។ នៅប៉ុន្មានឆ្នាំកន្លងទៅនេះ ភ្ញៀវទេសចរមិនត្រឹមតែបរិវេណអង្គរ និងប្រាសាទផ្សេងៗក្នុងតំបន់អង្គរទេ តែប្រាសាទ និងរមណីយដ្ឋានផ្សេងៗទៀត ដូចជាបេងមាលា កោះកេរ្តិ៍ ក្បាលស្ពាន ភ្នំគូលែន បន្ទាយឆ្មា និងសម្បូរព្រៃគុក សំរាប់រយៈពេល១ថ្ងៃ ។ ដំណើរកំសាន្តទៅកាន់ប្រាសាទឆ្ងាយៗ និងការបង្កើតផ្លូវដើរកំសាន្តពិជានធាតុទេសចរណ៍យ៉ាងសំខាន់ ។ ទោះ ជាយ៉ាងនេះក៏ដោយ តំបន់ទេសចរណ៍ឆ្ងាយៗទាំងនោះ ប្រឈមនឹងកង្វះខាតផ្លាកផ្តល់ព័ត៌មាន ហេដ្ឋារចនាសម្ព័ន្ធទេ.ចដែលមានលក្ខណៈសមស្របសំរាប់ភ្ញៀវបរទេស ។ ក្រៅពីការអភិវឌ្ឍន៍ និងកែលំអប្រាសាទ និងតំបន់រមណីយដ្ឋានឆ្ងាយៗទាំងនោះ ត្រូវការឱ្យមានការអភិវឌ្ឍន៍សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ក្នុងក្រុងសៀមរាប តំបន់អង្គរ តំបន់ទេសចរណ៍ និងវប្បធម៌ និងតំបន់ទន្លេសាបដើម្បីលើកកំពស់ការទាក់ទាញរបស់ខេត្ត ក៏ដូចជាតំបន់ ទេសចរណ៍ផ្សេងៗទៀត និងលើកកំពស់តំលៃបេតិកភណ្ឌ សិល្បៈ វប្បធម៌ ប្រពៃណីមូលដ្ឋាន ជាដើម ។

**គោលបំណងគំរោង :**

គំរោងមានគោលបំណងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍សំខាន់ៗនៅសៀមរាប និងលើកកំពស់ដំណើរកំសាន្តនៅតាមតំបន់បេតិកភណ្ឌខ្មែរ តាមរយៈការកែលំអ និងការអភិវឌ្ឍន៍សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ ។

**ទំរង់រូប/ផ្នែករបស់គំរោង និងកម្មវិធី :**

តំបន់គំរោងមាន ៤ ដូចខាងក្រោម :

១. តំបន់ឧទ្យានបេតិកភណ្ឌអង្គរ ( ១- កែលំអកន្លែងលក់ និងកន្លែងចត និង២-បំពាក់ភ្លើងតាមផ្លូវ និងផ្លាកសញ្ញា)

២. តំបន់ទេសចរណ៍វប្បធម៌ និងសោភ័ណភាពក្រុង ( ១-អភិវឌ្ឍវប្បធម៌ប្រពៃណីអង្គរ និងសារមន្ទីរសិក្សាវប្បធម៌ ២-អភិវឌ្ឍឧទ្យានរុក្ខជាតិ និងផ្កា និងមជ្ឈមណ្ឌលសិក្សាធម្មជាតិ ៣-បង្កើតស្ថាប័នជាតិទេសចរណ៍(វិទ្យាស្ថានបណ្តុះបណ្តាល និងសិក្សាទេសចរណ៍) ៤-បង្កើតមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ ( នៅឯមន្ទីរទេសចរណ៍ តំបន់ផ្សារចាស់ និងតាមចំណតឡាន) ៥-បង្កើតកន្លែងចំណតនៅតំបន់ផ្សារចាស់ និង៦-អភិវឌ្ឍសំណង់ផ្សារចាស់បច្ចុប្បន្នឡើងវិញ)

៣. *តំបន់ទន្លេសាប និងជនបទ ( ១-កែលំអកន្លែងទេសចរណ៍នៅចុងឃ្នាស* ( កន្លែងព័ត៌មានទេសចរណ៍ បង្គន់ ផ្លាកសញ្ញា កន្លែងសំរាក និងកន្លែងចត) ២-កែលំអតំបន់ភ្នំក្រោម ( កន្លែង សម្លឹងមើល កន្លែងសំរាក បង្គន់ កន្លែងចត និងផ្លាកសញ្ញា)

៤. តំបន់ឆ្ងាយពីរមណីយដ្ឋានអង្គរ ( អភិវឌ្ឍន៍បណ្តាញបេតិកភណ្ឌខ្មែរ) កែលំអ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទេសចរណ៍នៅស្ពានធ្មោព សម្បូរព្រៃគុក បឹងមាលា ភ្នំគូលែន ក្បាលស្ពាន កោះកេរ្តិ៍ បន្ទាយឆ្មា ព្រះវិហារ តំបន់ប្រាសាទនៅបាត់ដំបង ។

**លទ្ធផលគំរោង :**

សៀមរាបនឹងក្លាយជាតំបន់ទេសចរណ៍វប្បធម៌យ៉ាងទាក់ទាញដែលមានផលិតផលទេសចរណ៍ផ្សេងៗ ការអភិវឌ្ឍន៍បណ្តាញទេសចរណ៍ខ្មែរ និងពិពិធកន្លែងកំសាន្តផ្សេងៗ ។ គំរោងនេះនឹងជួយបង្វែរភ្ញៀវទេសចរចេញពីតំបន់អង្គរនៅពេល និងរដូវមានភ្ញៀវច្រើន និងបង្កើនការស្នាក់នៅយូររបស់ភ្ញៀវនៅសៀមរាប ។

**ឥទ្ធិពលលើបរិស្ថាន និងសង្គម :**

គំរោងនឹងជ្រើសរើសទីកន្លែង អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម ដែលមានផលប៉ះពាល់តិចតួចដល់បរិស្ថាន និងសង្គម ។

**គំរោងពាក់ព័ន្ធ :**

១. គំរោងអភិវឌ្ឍសហគមន៍ ( ធ្វើវត្ថុអនុស្សាវរីយ៍ដោយដៃ) ដែលទទួលបានថវិកាពី GTZ ក្នុងតំបន់សម្បូរព្រៃគុក និងដែលបានចាប់ផ្តើមនៅ ២០០៤

២. កែលំអផ្លូវនៅក្នុង និងជុំវិញតំបន់ផ្សារចាស់ដោយសាលាខេត្តសៀមរាប ដែលចាប់ផ្តើមនៅខែឆ្នូ ២០០៥

**កាលវិភាគអនុវត្ត :**

១. ២០០៦ : ស្នើ និងរៀបចំ

២. ២០០៧ : សិក្សាលទ្ធិភាព

៣. ២០០៨ : រៀបចំលំអិត

៤. ២០០៩ : ដេញថ្លៃ និងផ្តល់គំរោង

៥. ២០០៩-១១ : សាងសង់

៦. ២០១២ : កសាងសមត្ថភាពអនុវត្ត និងគ្រប់គ្រង

**ការចំណាយសំរាប់គំរោង ( ០០០ ដុល្លារ)**

| | |
|---|---|
| ១. ចំណាយផ្ទាល់ | ២០.០០០ |
| ២. ការអភិវឌ្ឍន៍សមត្ថភាព | ៥០០ |
| ៣. ប្រាក់បំរុងប្បវិទ្ធ | ២.០០០ |
| ៤. *ការបង្កើនតំលៃ* | ២.០៥០ |
| ៥. សេវាកម្មវិស្វកម្ម | ២.០០០ |
| ៦. ការទិញដី | - |
| សរុប | ២៦.៥៥០ |

## វិស័យ : ការអភិវឌ្ឍន៍វិស័យទេសចរណ៍

| លេខកូដ | ឈ្មោះគម្រោង | អ្នកទទួលផល ឬក្រុមគោលដៅ | ថវិកាដែលបានស្នើ | តំលៃប៉ាន់ស្មាន | អាទិភាពគម្រោង |
|---|---|---|---|---|---|
| TO-3 | កម្មវិធីលើកកំពស់គុណភាពទេសចរណ៍តាមរយៈភាពជាដៃគូរវាងរដ្ឋ និងឯកជន | ភ្ញៀវ ប្រ.ជ ជំនួញ និងវិស័យឯកជន (ទេ.ច និងសេវាកម្មក្នុងស.រ) | ជំនួយបរទេស | និងកំណត់នៅពេលក្រោយ | អាទិភាព |

| ទីតាំងគម្រោង | ទីភ្នាក់ងារអនុវត្ត | មន្ទីរ | អ្នកទទួលទំនាក់ទំនង | ទូរស័ព្ទ | អ៊ីមែល |
|---|---|---|---|---|---|
| ខេត្តសៀមរាប | មន្ទីរទេសចរណ៍ (ស.រ) ក្រសួងទេសចរណ៍ និងអប្សរា | | | | |

**ប្រវត្តិ :**

សៀមរាបបាន និងកំពុងក្លាយជាតំបន់ទេសចរណ៍ប្រមូលផ្ដុំយ៉ាងលឿន។ ទោះជាយ៉ាងនេះក្ដី តំបន់ក្រុង និងកន្លែងទេសចរណ៍ពុំទាន់មានការគ្រប់គ្រងឱ្យបានសមរម្យសំរាប់បំរើភ្ញៀវទេសចរបរទេសប្រកបដោយផាសុកភាព និងសុវត្ថិភាពនៅឡើយ។ កង្វះខាតសកម្មភាពទីផ្សារ និងការផ្សព្វផ្សាយទេសចរណ៍របស់រដ្ឋគឺជាឧបសគ្គសំរាប់សៀមរាបក្នុងការប្រែក្លាយសៀមរាបឱ្យទៅជាតំបន់ទេសចរណ៍គុណភាព។ ការលើកកំពស់គុណភាពទេសចរណ៍នៅសៀមរាបតាមរយៈភាពជាដៃគូរវាងរដ្ឋ និងឯកជន គឺជាការចាំបាច់ដើម្បីលើកកំពស់តំលៃបេតិកភណ្ឌខ្មែរ។

**គោលបំណងគម្រោង :**

គំរោងនេះមានគោលបំណងលើកកំពស់តំលៃបេតិកភណ្ឌខ្មែរតាមរយៈការរៀបចំសកម្មភាពវប្បធម៌ ប្រពៃណីក្នុងស្រុក ពង្រឹងភាពជាដៃគូរវាងរដ្ឋ និងឯកជនតាមរយៈការបង្កើតគណៈកម្មការដឹកនាំសំរាប់ការផ្សព្វផ្សាយ និងទីផ្សារ រៀបចំផែនការទីផ្សារជាយុទ្ធសាស្ត្រ អនុវត្តយុទ្ធនាការលើកកំពស់ការយល់ដឹងជាសាធារណៈ និងរៀបចំគោលការណ៍ណែនាំទេសចរណ៍សំរាប់កែលំអគុណភាពទេសចរណ៍នៅសៀមរាប។

**ទំរង់រូប/ផ្នែករបស់គំរោង និងកម្មវិធី :**

១. បង្កើតគណៈកម្មការដឹកនាំទីផ្សារ និងលើកកំពស់ទេសចរណ៍នៅសៀមរាប

២. រៀបចំផែនការជាយុទ្ធសាស្ត្រសំរាប់លើកកំពស់ទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍នៅសៀមរាប

៣. ពង្រឹងសមត្ថភាពទាក់ទងនឹងវិស័យទេសចរណ៍នៅសៀមរាបដោយការបញ្ជូនចេញជំនាញការទេសចរណ៍អន្តរជាតិ (ការផ្សព្វផ្សាយ និងទីផ្សារទេសចរណ៍ ការអភិវឌ្ឍន៍/ការគ្រប់គ្រងធនធានមនុស្ស អ្នកឯកទេសមូលដ្ឋានទិន្នន័យ/បច្ចេកវិទ្យាព័ត៌មានវិទ្យា ការអភិវឌ្ឍន៍ផលិតផលសំរាប់វិស័យទេសចរណ៍)

៤. កម្មវិធីភាពជាដៃគូរវាងរដ្ឋ និងឯកជន

- កម្មវិធី និងយុទ្ធនាការលើកកំពស់ការយល់ដឹងជាសាធារណៈ
- ការលើកកំពស់ជំនាញបដិសណ្ឋារកិច្ចសំរាប់វិស័យជំនួញទេសចរណ៍
- រៀបចំ និងដាក់តាំងព្រឹត្តិការណ៍ និងវេទិកាផ្សេងៗ

៥. ការចូលរួមកម្មវិធីបណ្ដុះបណ្ដាលទាក់ទងនឹងវិស័យទេសចរណ៍របស់មន្ត្រីរដ្ឋាភិបាលក្នុងប្រទេសជប៉ុន។

**លទ្ធផលគំរោង :**

លទ្ធផលផ្ទាល់របស់គំរោងគឺការពង្រឹងសមត្ថភាពលើការផ្សព្វផ្សាយ និងទីផ្សារទេសចរណ៍តាមរយៈភាពជាដៃគូរវាងរដ្ឋ និងឯកជន និងលើកកំពស់សេវាកម្ម និងគុណភាពទេសចរណ៍សំរាប់ស្លាកសញ្ញាទីផ្សារទេសចរណ៍គុណភាពនៅសៀមរាប។

**ឥទ្ធិពលលើសង្គម និងបរិស្ថាន :**

កម្មវិធីនេះនឹងគ្មានផលប៉ះពាល់អ្វីមានដល់សង្គម និងបរិស្ថានឡើយ។

**គំរោងពាក់ព័ន្ធ :**

**កាលវិភាគអនុវត្ត :**

២០០៦ : រៀបចំគំរោង

២០០៧-២០០៩ : ១. បង្កើតភាពជាដៃគូរវាងរដ្ឋ និងឯកជនសំរាប់ផ្សព្វផ្សាយ និងទីផ្សារទេសចរណ៍ ២. បញ្ជូនជំនាញការទេសចរណ៍បរទេស ៣. រៀបចំទីផ្សារយុទ្ធសាស្ត្រ

២០១០-២០១២ : ១. កម្មវិធីភាពជាដៃគូរវាងរដ្ឋ និងឯកជន ២. បណ្ដុះបណ្ដាលមន្ត្រីរដ្ឋាភិបាល (ទទួលបន្ទុកលើការងារទេសចរណ៍)

**ការចំណាយរបស់គំរោង (០០០ ដុល្លារ)**

| | |
|---|---|
| ១. ចំណាយផ្ទាល់ | - |
| ២. ការកសាងសមត្ថភាព | - |
| ៣. ប្រាក់បំរុងរូបវ័ន្ត | - |
| ៤. ការបង្កើនតំលៃ | - |
| ៥. សេវាកម្មវិស្វកម្ម | - |
| សរុប | - |

## JICA - ការសិក្សាអំពីផែនការមេរួមសំរាប់ការអភិវឌ្ឍន៍ក្រុងសៀមរាប/អង្គរប្រកបដោយនិរន្តរភាព

### សេចក្តីសង្ខេបគំរោង

### វិស័យ : ការពង្រីកវិស័យកសិកម្ម និងផលិតផលក្នុងស្រុក

| លេខកូដ | ឈ្មោះគំរោង | អ្នកទទួលផល ឬក្រុមគោលដៅ | ថវិកាដែលបានសន្មត | តំលៃប៉ាន់ស្មាន | អាទិភាពគំរោង |
|---|---|---|---|---|---|
| A-1 | អភិវឌ្ឍធនធានមនុស្ស និងការបង្កើតមជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលក្នុងស្រុក | អ្នកផលិតវត្ថុធ្វើដោយដៃក្នុងស្រុក និងផលិតផលកសិកម្ម | ជំនួយបរទេស | ៨០ (០០០ដុល្លារ) | អាទិភាព |

| ទីតាំងគំរោង | ទីភ្នាក់ងារអនុវត្ត | មន្ទីរ | អ្នកទទួលទំនាក់ទំនង | ទូរស័ព្ទ | អ៊ីម៉ែល |
|---|---|---|---|---|---|
| ខេត្តសៀមរាប | អាជ្ញាធរខេត្ត | | | | |

**ប្រវត្តិ :**

១. សមត្ថភាពស្ថាប័ន និងសមត្ថភាពមនុស្ស ជាពិសេស សមត្ថភាពធ្វើផែនការរបស់អាជ្ញាធរខេត្តមិនទាន់គ្រប់គ្រាន់សំរាប់ផ្សព្វផ្សាយ និងដឹកនាំជំនួញនៅមូលដ្ឋាននៅឡើយ

២. អាជ្ញាធរខេត្តកំពុងខ្វះខាតលើការសំរបសំរួលដ៏ស៊ីជំរៅ ឬផ្នែកមូលដ្ឋានគ្រឹះមួយសំរាប់សកម្មភាពលើកកំពស់ផលិតផលក្នុងស្រុក។

**គោលបំណងគំរោង :**

១) ដើម្បីអភិវឌ្ឍធនធានមនុស្សសំរាប់សកម្មភាពណែនាំជំនួញដែលទាក់ទងនឹងវិស័យទេសចរណ៍

២) បង្កើតមជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលក្នុងស្រុក ដូចជា មជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលអង្គរ ។ មជ្ឈមណ្ឌលនេះនឹងជួយជំនួញមូលដ្ឋាន និងសហគមន៍ ដោយការបង្កើតបណ្តាញព័ត៌មាន ការលើការលើកកំពស់ស្លាកដៃ និងបច្ចេកទេស ទំនាក់ទំនងសាធារណៈ និងការលើកកំពស់ការលក់ដូរ ។

**ទំរង់រូប/ផ្នែករបស់គំរោង និងកម្មវិធី :**

១.បណ្តុះបណ្តាលមន្ត្រីដឹកនាំ

២. បង្កើតមជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលអង្គរ

៣. ផ្សព្វផ្សាយផលិតផលក្នុងស្រុកតាមរយៈព័ត៌មាន ការផលិត និងការគាំទ្រខាងទីផ្សារ

**លទ្ធផលគំរោង**

១. អភិវឌ្ឍន៍ធនធានមនុស្ស

២. ជួយខាងផ្នែកព័ត៌មានសំរាប់ផ្សព្វផ្សាយផលិតផលក្នុងស្រុក និង ៣. ផលិតកម្ម និងការជួយខាងទីផ្សារសំរាប់លើកកំពស់ផលិតផលក្នុងស្រុក

**មជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលអង្គរ**

១. កែលំអគុណភាពផលិតផលមូលដ្ឋាន ដើម្បីជំនួសទំនិញនាំចូល

២. ភ្ជាប់ផលិតផលក្នុងស្រុកទៅនឹងជំនួញដែលទាក់ទងនឹងទេសចរណ៍

៣. លើកកំពស់ប្រាក់ចំណូល និងពង្រីកសេដ្ឋកិច្ចរបស់កសិករ/ប្រជាជនក្នុងស្រុក

**គំរោងពាក់ព័ន្ធ**

ការតាំងពិព័រណ៍ផលិតផលអង្គរ ២០០៥ (គំរោងសាកល្បង)

**កាលវិភាគអនុវត្ត**

១. បណ្តុះបណ្តាល៣ ខែក្នុងប្រទេសជប៉ុន

២. ជំហាន ១ រយៈពេល ១ ឆ្នាំ

៣. សកម្មភាពពេញលេញ (បន្ទាប់ពីជំហាន ១)

**ការចំណាយលំអិតរាប់គំរោង (០០០ ដុល្លារ)**

| | |
|---|---|
| ១. ចំណាយផ្ទាល់ | ១៦ |
| ២. ការកសាងសមត្ថភាព | ៥៤ |
| ៣. ប្រាក់បំរុងប្រើ | ២ |
| ៤. ការបង្កើនតំលៃ | ៧ |
| ៥. សោហ៊ុយវិស្វកម្ម | ២ |
| ៦. ការទិញដី | - |
| សរុប | ៨០ |

**JICA - ការសិក្សាអំពីផែនការមេរួមសំរាប់ការអភិវឌ្ឍន៍ក្រុងសៀមរាប/អង្គរប្រកបដោយនិរន្តរភាព**

**សេចក្ដីសង្ខេបគំរោង**

**វិស័យ : ធនធានទឹក និងការផ្គត់ផ្គង់ទឹក**

| ល.កូដ | ឈ្មោះគំរោង | អ្នកទទួលផល ឬក្រុមគោលដៅ | ថវិកាដែលបានសន្មត | តំលៃប៉ាន់ស្មាន | អាទិភាពគំរោង |
|---|---|---|---|---|---|
| W-3 | ការប្ដូរបំពង់ទឹកចាស់ | អ្នកប្រើប្រាស់សេវាកម្មទឹកសាធារណៈទាំងអស់ | SRWSA និងកម្ចី | ៤៥០ (000ដុល្លារ) | អាទិភាព |

| ទីតាំងគំរោង | ទីភ្នាក់ងារអនុវត្ត | មន្ទីរ | អ្នកទទួលទំនាក់ទំនង | ទូរស័ព្ទ | អ៊ីម៉ែល |
|---|---|---|---|---|---|
| តំបន់ភាគពាយព្យនៃប្រទេសកម្ពុជា | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ផ្នែកផ្គត់ផ្គង់ទឹកផឹក | ទេង សាក់ដា | | |

**ប្រវត្តិ :**

ប្រព័ន្ធបែងចែកទឹកបច្ចុប្បន្ននៅតែប្រើបំពង់ទឹកចាស់ៗ ដែលមានប្រវែងប្រមាណជា ៦.៥ គីឡូម៉ែត្រ។

បំពង់ទឹកចាស់ៗទាំងនោះមានការលិចទឹក និងធ្វើឱ្យគុណភាពទឹកធ្លាក់ចុះ។

ដើម្បីកាត់បន្ថយការលិចទឹក និងកែលំអគុណភាពនៃការផ្គត់ផ្គង់ទឹក ចាំបាច់ត្រូវផ្លាស់ប្ដូរបំពង់ចាស់ៗទាំងនោះជាបន្ទាន់។

**ទំរង់រូប/ផ្នែករបស់គំរោង និងកម្មវិធី :**

ការងារផ្លាស់ប្ដូរបំពង់ចាស់ដែលមានចំងាយប្រមាណជា ៦.៥ គ.ម ដោយរួមបញ្ចូលទាំងគ្រឿងបំលាស់ចាំបាច់ជាច្រើនទៀត ដូចជា វ៉ាល់ទឹក និងនាឡិកាស្ទង់ផ្សេងៗទៀត។

**គោលបំណងគំរោង :**

១. កាត់បន្ថយការលិចទឹក

២. កែលំអគុណភាពនៃការផ្គត់ផ្គង់ទឹក

**លទ្ធផលរបស់គំរោង :**

បំពង់ផ្គត់ផ្គង់ទឹកថ្មី

**ឥទ្ធិពលលើសង្គម និងបរិស្ថាន :**

១. កាត់បន្ថយផលប៉ះពាល់អវិជ្ជមានដល់សុខភាព ដែលបណ្ដាលមកពីការផ្គត់ផ្គង់ទឹក

**គំរោងពាក់ព័ន្ធ :**

១.ការសិក្សាអំពីគំរោងកែលំអប្រព័ន្ធផ្គត់ផ្គង់ទឹកក្នុងក្រុងសៀមរាប (JICA)

**កាលវិភាគអនុវត្ត :**

| | |
|---|---|
| ១. ការងារលទ្ធកម្ម | មេសា ០៦ - មិថុនា ០៦ |
| ២. ការងារសាងសង់ | កក្កដា ០៦ - មីនា ០៧ |

**ការចំណាយសំរាប់គំរោង (០០០ ដុល្លារ)**

| | |
|---|---|
| ១. ចំណាយផ្ទាល់ | ៣៧៥ |
| ២. កសាងសមត្ថភាព | |
| ៣. ប្រាក់បំរុងរូបវ័ន្ត | ៣៨ |
| ៤. ការបង្កើនតំលៃ | ៣៨ |
| ៥. សេវាកម្មវិស្វកម្ម | - |
| ៦. ពិញជី | - |
| សរុប | ៤៥០ |

## JICA - ការសិក្សាអំពីផែនការមេសម្រាប់ការអភិវឌ្ឍន៍ក្រុងសៀមរាប/អង្គរប្រកបដោយនិរន្តរភាព

### សេចក្ដីសង្ខេបគំរោង

### វិស័យ : ការដឹកជញ្ជូន

| លេខកូដ | ឈ្មោះគំរោង | អ្នកទទួលផល ឬក្រុមគោលដៅ | ថវិកាដែលបានសន្មត | តំលៃប៉ាន់ស្មាន | អាទិភាពគំរោង |
|---|---|---|---|---|---|
| TR-1 | គំរោងកែលំអស្ពានពីសម័យបារាំង | ប្រជាជននៅសៀមរាប និងភ្ញៀវទេសចរ | ជំនួយឥតសំណង | ១.០០០ (០០០ដុល្លារ) | អាទិភាព |

| ទីតាំងគំរោង | ទីភ្នាក់ងារអនុវត្ត | មន្ទីរ | អ្នកទទួលទំនាក់ទំនង | ទូរស័ព្ទ | អ៊ីមែល |
|---|---|---|---|---|---|
| ក្រុងសៀមរាប | ក្រសួងសាធារណការ និងដឹកជញ្ជូន | មន្ទីរសាធារណការ និងដឹកជញ្ជូន | | | |

**ប្រវត្តិ :**

១. ស្ពានថ្មបច្ចុប្បន្ននៅតាមបណ្ដោយផ្លូវជាតិលេខ៦ ដែលហៅថាស្ពានបារាំងពីជាកន្លែងស្ទះចរាចរណ៍បំផុតនៅសៀមរាប

២. ក្រសួងសាធារណការ និងដឹកជញ្ជូនបានចាប់ផ្ដើមសាងសង់ស្ពានបណ្ដោះអាសន្នដែលមានចំងាយប្រមាណជា ២០០ ម៉ែត្រ

នៅខាងលើស្ទឹងសំរាប់ចរាចរណ៍ពីខាងកើតទៅលិចដើម្បីដោះស្រាយការស្ទះចរាចរណ៍ជាបណ្ដោះអាសន្ន។

**គោលបំណងគំរោង :**

១. ដោះស្រាយការស្ទះចរាចរណ៍ដោយការសាងសង់ស្ពានថ្មីដែលស្របនឹងស្ពានបារាំង។

**ទំរង់រូប/វិធីករបស់គំរោង និងកម្មវិធី :**

១. សាងសង់ស្ពានថ្មីនៅក្បែរស្ពានបច្ចុប្បន្ន

- ប្រវែងស្ពាន ៤០ ម៉ែត្រ

- ស្ពានថ្មីនឹងប្រើប្រាស់សំរាប់ចរាចរណ៍ពីទិសខាងកើតទៅលិច ចំណែកស្ពានបច្ចុប្បន្នបំរើពីលិចទៅកើត

២. កែលំអរង្វង់មូលនៅចុងស្ពានភាគខាងលិច

**លទ្ធផលគំរោង :**

១. នៅពេលមានស្ពានថ្មី លំហូរចរាចរណ៍នៅតាមផ្លូវជាតិលេខ៦ នឹងមានភាពប្រសើរឡើង

**ឥទ្ធិពលលើសង្គម និងបរិស្ថាន :**

១. បំពង់ទឹក និងបំពង់ផ្សេងៗទៀតដែលរកប់នៅក្បែរស្ពាននិងរងការប៉ះពាល់ដោយសារសកម្មភាពសាងសង់ស្ពាន។

**គំរោងពាក់ព័ន្ធ**

១. ស្ពានបង្វែរចរាចរបច្ចុប្បន្នកំពុងសាងសង់ក្នុងចំងាយប្រមាណ ២០០ ម៉ែត្រពីស្ពានបារាំង

**កាលវិភាគអនុវត្ត :**

| | |
|---|---|
| ១. មិញ្ញី | មីនា ០៦ - កញ្ញា ០៧ |
| ២. រៀបចំផ្ដល់មូលនិធិ | មីនា ០៦ - កញ្ញា ០៧ |
| ៣. សិក្សាលទ្ធិផលទទួលផល និងការងារលំអិត | កញ្ញា ០៦ - ធ្នូ ០៦ |
| ៤. ដេញថ្លៃ និងផ្ដល់គំរោង | មករា ០៧ - មីនា ០៧ |
| ៥. សាងសង់ | មីនា ០៧ - ធ្នូ ០៧ |

**ការចំណាយសំរាប់គំរោង (០០០ ដុល្លារ)**

| | |
|---|---|
| ១. ចំណាយផ្ទាល់ | ៧១៣ |
| ២. ការត្រៀមទុករូបវ័ន្ត | ៧១ |
| ៣. ការបង្កើនតំលៃ | ៧១ |
| ៤. សេវាកម្មវិស្វកម្ម | ៧១ |
| ៥. មិញ្ញី | ៣០ |
| សរុប | ៩៥៧ |

សេចក្ដីសង្ខេបគំរោង

វិស័យ : ការដឹកជញ្ជូន

| ល.កូដ | ឈ្មោះគំរោង | | អ្នកទទួលផល ឬក្រុមគោលដៅ | | ថវិកាដែលបានសន្មត | តំលៃប៉ាន់ស្មាន | អាទិភាពគំរោង |
|---|---|---|---|---|---|---|---|
| TR-2 | គំរោងបណ្ដាញផ្លូវវាងរាប ( ដំណាក់ ១ ) | | ប្រជាជននៅសៀមរាប និងភ្ញៀវទេសចរ | | ជំនួយបរទេស | ១០.៨០០ (០០០ដុល្លារ) | អាទិភាព |
| ទីតាំងគំរោង | | ទីភ្នាក់ងារអនុវត្ត | មន្ទីរ | អ្នកទទួលទំនាក់ទំនង | ទូរស័ព្ទ | | អ៊ីម៉ែល |
| ក្រុងសៀមរាប | | អាជ្ញាធរខេត្ត | មន្ទីរសាធារណការ និងដឹកជញ្ជូន | | | | |

**ប្រវត្តិ :**

១. ធ្វើការកែលំអតំបន់ផ្លូវនៅតាមសណ្ឋាគារ និងភោជនីយដ្ឋានដែលស្ថិតនៅតាមបណ្ដោយផ្លូវជាតិលេខ៦

២. ការធ្វើចរាចរមកផ្ទុំនៅតាមផ្លូវជាតិលេខ៦ ដោយសារកង្វះខាតបណ្ដាញផ្លូវធំ១ និងបណ្ដាញផ្លូវវាងរាប ជាពិសេសសំរាប់ចលនាចរាចរណ៍ពីទិសខាងកើតទៅខាងលិច

៣. ការប៉ាន់ស្មានពីតំរូវការផ្នែកចរាចរណ៍បង្ហាញថា កំណើនចរាចរណ៍នឹងហួសសមត្ថភាពផ្លូវជាតិលេខ៦ក្នុងក្រុងនៅពេលដ៏ខ្លីខាងមុខ

៤. ស្ថានភាពផ្លូវមិនល្អ

**គោលបំណងគំរោង :**

១. ដើម្បីកាត់បន្ថយការស្ទះចរាចរណ៍នៅតាមបណ្ដោយផ្លូវជាតិលេខ៦ ដោយការសាងសង់បណ្ដាញផ្លូវវាងរាប ជាពិសេសសំរាប់ចលនាចរាចរណ៍ពីទិសខាងកើតមកលិច

២. ដើម្បីកែលអស្ថានភាពផ្លូវនៅក្នុងតំបន់លំនៅដ្ឋាន

**ទំរង់រូប/ផ្នែករបស់គំរោង និងកម្មវិធី :**



១. ផ្លូវភាគខាងជើង ( ផ្លូវចរាចរណ៍ពីរទិស និងផ្លូវដើរ ) ក.សង់ផ្លូវថ្មីប្រហែល ៤.១ គ.ម ខ. ពង្រីកផ្លូវបច្ចុប្បន្នប្រមាណ ១.៦ គ.ម គ. សាងសង់ស្ពានស៊ីម៉ងត៍ប្រមាណ ៣០ ម៉ែត្រ

២. ផ្លូវភាគខាងត្បូង ( ផ្លូវចរាចរណ៍ពីរទិស និងផ្លូវដើរ ) ក.សង់ផ្លូវថ្មីប្រហែល ១.២ គ.ម ខ. ពង្រីកផ្លូវបច្ចុប្បន្នប្រមាណ ៤ គ.ម គ.)

៣. ផ្លូវភ្ជាប់ ( ផ្លូវចរាចរណ៍ពីរទិស និងផ្លូវដើរ ) ក.សង់ផ្លូវថ្មីប្រហែល ០.៨ គ.ម ខ. ពង្រីកផ្លូវបច្ចុប្បន្នប្រមាណ ១.៧ គ.ម)

- ១. និង ២. នឹងធ្វើឡើងដោយចាក់កៅស៊ូ
- ៣. នឹងធ្វើឡើងដោយប្រើ DBST ។

**លទ្ធផលគំរោង :**

១. បំបែកការស្ទះចរាចរណ៍ពីផ្លូវជាតិលេខ៦

២. ជំរុញការអភិវឌ្ឍន៍នៅតំបន់ផ្សេង១ទៀត ក្រៅពីតាមបណ្ដោយផ្លូវជាតិលេខ៦

៣. បំបែកការធ្វើចរាចរណ៍របស់ប្រជាជនមូលដ្ឋានពីការធ្វើចរាចរណ៍របស់ភ្ញៀវ

**ឥទ្ធិពលលើសង្គម និងបរិស្ថាន :**

១. មិនអាចចៀសផុតពីការបង្វែរការតាំងទីលំនៅនៅតាមកន្លែងពង្រីក/សាងសង់ផ្លូវឡើយ ។

**គំរោងពាក់ព័ន្ធ :**

១. គំរោងសាងសង់ផ្លូវឆ្លងកាត់ ដែលមានឈ្មោះថា KOICA

**កាលវិភាគអនុវត្ត :**

| | |
|---|---|
| ១. មិញ្ញឺ | មីនា ០៦ - កញ្ញា ០៧ |
| ២. រៀបចំផ្ដល់មូលនិធិ | កក្កដា ០៦ - ធ្នូ ០៧ |
| ៣. សិក្សាលម្អិតលទ្ធភាព និងការងារលំអិត | មករា ០៧ - កញ្ញា ០៧ |
| ៤. ដេញថ្លៃ និងផ្ដល់គំរោង | តុលា ០៧ - ធ្នូ ០៧ |
| ៥. សាងសង់ | មករា ០៨ - ធ្នូ ០៨ |

**ការចំណាយលំអិតរាប់គំរោង ( ០០០ ដុល្លារ )**

| | |
|---|---|
| ១. ចំណាយសាងសង់ ( ខ.ជ =២.៨៤១ ខ.ត = ២.០៣២ ផ្លូវភ្ជាប់ = ៤៧៤ ) | |
| ២. ប្រាក់បំរុងរូបវ័ន្ត | ៥៣៥ |
| ៣. ការបន្ថែមតំលៃ | ៥៣៥ |
| ៤. សេវាកម្មវិស្វកម្ម | ៥៣៥ |
| ៥. មិញ្ញឺ | ៣.៨៨៨ |
| សរុប | ១០.៨៣៩ |

| ល.កូដ | ឈ្មោះគំរោង | | អ្នកទទួលផល ឬក្រុមគោលដៅ | | ថវិកាដែលបានសន្មត | តំលៃប៉ាន់ស្មាន | អាទិភាពគំរោង |
|---|---|---|---|---|---|---|---|
| TR-7 | គំរោងស្តារបណ្តាញផ្លូវនៅតាមតំបន់បេតិកភណ្ឌនៅជនបទ | | ប្រជាជននៅជនបទ និងភ្ញៀវទេសចរ | | ជំនួយ/កម្ចីបរទេស | ៣៣,២០០ (០០០ដុល្លារ) | អាទិភាព |
| ទីតាំងគំរោង | | ទីភ្នាក់ងារអនុវត្ត | មន្ទីរ | អ្នកទទួលទំនាក់ទំនង | ទូរស័ព្ទ | | អ៊ីមែល |
| តំបន់ពាយព្យនៃប្រទេសកម្ពុជា | | មន្ទីរសាធារណការ និងដឹកជញ្ជូន | | | | | |

**ប្រវត្តិ :**

១. សកម្មភាពទេសចរណ៍មានកំរិតហួសហេតុនៅតាមតំបន់ទេសចរណ៍នៃប្រាសាទអង្គរវត្ត

២. មានបេតិកភណ្ឌជាច្រើនទៀតដែលពុំបានអភិវឌ្ឍ និងស្តារនៅឡើយក្នុងតំបន់ជនបទ

៣. លទ្ធភាពចូលដល់តំបន់បេតិកភណ្ឌដាច់ស្រយាលទាំងនោះមានការលំបាក ជាពិសេសនៅរដូវវស្សា

**គោលបំណងគំរោង :**

១. បង្វែរទិសដៅទេសចរណ៍ចេញពីតំបន់ប្រាសាទអង្គរវត្ត និងតំបន់បេតិកភណ្ឌល្បីល្បាញផ្សេងៗទៀត

២. ផ្តល់កន្លែងទេសចរណ៍ផ្សេងៗទៀត ក្រៅពីរមណីយដ្ឋានប្រាសាទអង្គរវត្ត

៣. បង្កើតបណ្តាញផ្លូវដែលធន់នឹងអាកាសធាតុនៅតំបន់ជនបទ

**ទំរង់រូប/ផ្នែករបស់គំរោង និងកម្មវិធី :**

១. ការស្តារផ្លូវនានាឡើងវិញរវាងសៀមរាប និងតំបន់បេតិកភណ្ឌដូចក្នុងបញ្ជីខាងក្រោមឱ្យធន់នឹងអាកាសធាតុ ( សរុបប្រមាណជា ៣០០គ.ម )

- ក្បាលស្ពាន
- បាត់ដំ
- ព្រះវិហារ
- កោះកេរ្តិ៍ និង
- ភ្នំគូលេន

សូមបញ្ជាក់ថា ផ្លូវទៅកាន់បេងមាលា សម្បូរព្រៃគប់ និងបន្ទាយឆ្មាកំពុងស្តារឡើងវិញ




**លទ្ធផលគំរោង :**

១. ពង្រីកសកម្មភាពទេសចរណ៍ទៅកាន់តំបន់ទេសចរណ៍ផ្សេងៗទៀត

២. ផ្លូវល្អធន់នឹងអាកាសធាតុក្នុងតំបន់ជនបទ

**ឥទ្ធិពលលើសង្គម និងបរិស្ថាន :**

១. ព្រៃមួយចំនួនត្រូវកាប់សំរាប់ការពង្រីក ឬកែលម្អផ្លូវ

**គំរោងពាក់ព័ន្ធ :**

១. ADB ( គំរោងស្តារផ្លូវជាតិលេខ៦ពីស.រទៅពយប៉ែត ) ២. WB ( គំរោងហេដ្ឋារចនាសម្ព័ន្ធជនបទ និងខេត្ត ) ៣. ADB ( គំរោងអភិវឌ្ឍតំបន់ពាយព្យ ) ៤. រដ្ឋាភិបាលថៃ ( ការស្តារជាបន្ទាន់ផ្លូវជាតិលេខ៦ និងការសិក្សាជាក់ស្តែងសំរាប់ការស្តារ )

**កាលវិភាគអនុវត្ត :**

| | |
|---|---|
| ១. ទិញដី | មិថុនា ០៦ - ធ្នូ ០៧ |
| ២. រៀបចំផ្តល់មូលនិធិ | កក្កដា ០៦ - ធ្នូ ០៨ |
| ៣. សិក្សាសមិទ្ធិលទ្ធភាព និងការងារលំអិត | មករា ០៧ - កញ្ញា ០៩ |
| ៤. ដេញថ្លៃ និងផ្តល់គំរោង | តុលា ០៧ - ធ្នូ ០៩ |
| ៥. សាងសង់ | មករា ០៨ - ធ្នូ ១០ |

**ការចំណាយលំអិតរាប់គំរោង ( ០០០ ដុល្លារ )**

| | |
|---|---|
| ១. ចំណាយសាងសង់ | ២៥.៤០០ |
| ២. ប្រាក់បំរុងបរិវត្ត | ២.៥៥០ |
| ៣. ការបង្កើនតំលៃ | ២.៥៥០ |
| ៤. សេវាកម្មវិស្វកម្ម | ២.៥៥០ |
| ៥. ទិញដី | - |
| សរុប | ៣៣.១៥០ |

| ល.កូដ | ឈ្មោះគំរោង | អ្នកទទួលផល ឬក្រុមគោលដៅ | ថវិកាដែលបានសន្មត | តំលៃប៉ាន់ស្មាន | អាទិភាពគំរោង |
|---|---|---|---|---|---|
| W-4 | ការសិក្សាជាយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងទឹករួមនៅអាងស្ទឹងសៀមរាប និងរលួស | ប្រជាជន និងសកម្មភាពពាណិជ្ជកម្ម និងកសិកម្ម | ជំនួយបរទេស | ៧.២៨២ (000ដុល្លារ) | អាទិភាព |

| ទីតាំងគំរោង | ទីភ្នាក់ងារអនុវត្ត | មន្ទីរ | អ្នកទទួលទំនាក់ទំនង | ទូរស័ព្ទ | អ៊ីម៉ែល |
|---|---|---|---|---|---|
| អាងស្ទឹងសៀមរាប និងរលួស | ក្រសួងធនធានទឹក និងឧតុនិយម | រដ្ឋលេខាធិការ | វេង សុខុន | | |

**ប្រវត្តិ :**

កង្វះខាតទឹកជាពិសេសនៅរដូវប្រាំងសំរាប់កសិកម្ម ការផ្គត់ផ្គង់ទឹក និងបរិស្ថានបានក្លាយជាបញ្ហាធ្ងន់ធ្ងរ។ ជាងនេះទៀត កង្វះខាតទិន្នន័យ/ព័ត៌មានទាក់ទងនឹងធនធានទឹកបច្ចុប្បន្នធ្វើឱ្យមានការលំបាកដល់ការដោះស្រាយបញ្ហា។ ដើម្បីកែលំអការគ្រប់គ្រង និងនិរន្តរភាពធនធានទឹក ចាំបាច់ត្រូវធ្វើការសិក្សាជាយុទ្ធសាស្ត្រមួយស្តីពីការគ្រប់គ្រងធនធានទឹករួម។ ការសិក្សានេះគួរធ្វើឡើងចំពោះធនធានទឹកលើដី និងក្រោមដី ដើម្បីបំពេញតំរូវការនៃការប្រើប្រាស់ក្នុងវិស័យកសិកម្ម ការផ្គត់ផ្គង់ទឹក និងវិស័យបរិស្ថាន។

**ទំរង់រួម/ផ្នែករបស់គំរោង និងកម្មវិធី :**

១. បង្កើត និងរៀបចំប្រព័ន្ធត្រួតពិនិត្យ/វាស់វែងទឹកលើដី
២. ធ្វើការគណនាតំលាំងទឹកក្នុងអាងស្ទឹងទាំងពីរ
៣. អង្កេតទឹកក្រោមដី និងរៀបចំផែនទី (បែងចែក) ទឹកក្រោមដី
៤. បង្កើតផែនការគ្រប់គ្រងធនធានទឹករួម
៥. រៀបចំផែនការមេសំរាប់អភិវឌ្ឍធនធានទឹក
៦. រៀបចំព្រាងសិទ្ធិប្រើប្រាស់ធនធានទឹកនៅអាងស្ទឹងសៀមរាប និងរលួស
៧. ធ្វើការសិក្សាលទ្ធិលទ្ធភាពនៃគំរោងអាទិភាពផ្សេងៗ

**គោលបំណងគំរោង :**

១. បង្កើតប្រព័ន្ធត្រួតពិនិត្យ/វាស់ទឹកលើដីនៅអាងស្ទឹងសៀមរាប និងរលួស
២. ស្វែងយល់ឱ្យបានស៊ីជំរៅនូវស្ថានភាពបែងចែកទឹកក្រោមដី និងសក្តានុពលរបស់ទឹកក្រោមដីនេះ
៣. កំណត់សមត្ថភាព/សក្តានុពលធនធានទឹក ទាំងទឹកលើដី ទាំងទឹកក្រោមដី
៤. បង្កើតផែនការគ្រប់គ្រងធនធានទឹករួម
៥. រៀបចំផែនការមេសំរាប់ការអភិវឌ្ឍន៍ធនធានទឹក

**លទ្ធផលរបស់គំរោង :**

១. កំរិតទឹកលើដី និងប្រព័ន្ធវាស់កំរិតទឹកហូរ ២. ផែនការគ្រប់គ្រងធនធានទឹករួម ៣. ផែនការមេអំពីការអភិវឌ្ឍន៍ធនធានទឹក ៤. ការសិក្សាលទ្ធិលទ្ធភាពនៃគំរោងអាទិភាពផ្សេងៗ

**ឥទ្ធិពលលើសង្គម និងបរិស្ថាន :**

១. កំណើនចំនួននៃការប្រើប្រាស់ទឹកដោយការគ្រប់គ្រងធនធានទឹកសមរម្យ ២. លើកកំពស់សកម្មភាពកសិកម្ម និងផលិតកម្មនៅរដូវប្រាំង ៣. កាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើសុខភាពដែលបណ្តាលមកពីកង្វះខាតការផ្គត់ផ្គង់ទឹក ៤. កែលំអអនាម័យតាមស្ទឹង និងផ្តល់សោភ័ណភាពសមស្របទៅនឹងបេតិកភណ្ឌអង្គរ

**គំរោងពាក់ព័ន្ធ :**

១. គំរោងលើកកំពស់បាយណ៍ខាងលិច (រដ្ឋាភិបាលឥណ្ឌា) ២. គំរោងផ្គត់ផ្គង់ទឹកនៅទីរួមខេត្តសៀមរាប (ADB)
៣. ការសិក្សាអំពីប្រព័ន្ធផ្គត់ផ្គង់ទឹកសំរាប់តំបន់សៀមរាប (JICA) ៤. ការប៉ាន់ស្មានដំបូងពីលំហូរ និងសមត្ថភាពទឹករបស់អង្គរ

**កាលវិភាគអនុវត្ត :**

| | |
|---|---|
| ១. ការរៀបចំប្រព័ន្ធវាស់ទឹក | មករា ០៧ - មិថុនា ០៧ |
| ២. ផែនការគ្រប់គ្រង និងផែនការមេ | មីនា ០៧ - ធ្នូ ០៨ |
| ៣. សិក្សាលទ្ធិលទ្ធភាព | តុលា ០៨ - មិថុនា ០៩ |

**ការចំណាយលើគំរោង (000 ដុល្លារ)**

| | |
|---|---|
| ១. ចំណាយផ្ទាល់ | ៦.៦២០ |
| ២. កសាងសមត្ថភាព | |
| ៣. ប្រាក់បំរុងប៉ាន់ប្រមាណ | |
| ៤. ការបង្កើនតំលៃ | ៦៦២ |
| ៥. សេវាកម្មវិស្វកម្ម | - |
| ៦. ដីធ្លី | - |
| សរុប | ៧.២៨២ |

| ល.កូដ | ឈ្មោះគំរោង | អ្នកទទួលផល ឬក្រុមគោលដៅ | ថវិកាដែលបានសន្មត | តំលៃប៉ាន់ស្មាន | អាទិភាពគំរោង |
|---|---|---|---|---|---|
| SD-2 | គំរោងអភិវឌ្ឍន៍ក្រុង ( សៀមរាប/អង្គរ ) | ប្រជាជន សណ្ឋាគារ និងជំនួញនៅស្រុកភាគខាងកើត | ជំនួយ AFD | ៤.៨០០ ( ០០០ដុល្លារ ) | អាទិភាព |

| ទីតាំងគំរោង | ទីភ្នាក់ងារអនុវត្ត | មន្ទីរ | អ្នកទទួលទំនាក់ទំនង | ទូរស័ព្ទ | អ៊ីម៉ែល |
|---|---|---|---|---|---|
| ស្រុកភាគខាងកើត( តំបន់១ តំបន់២ និងតំបន់៣ ) | មន្ទីរសាធារណការ និងដឹកជញ្ជូន និងអប្សរា | | លោក Yves Teeracol AFD | | |

**ប្រវត្តិ :**

តំបន់ដែលស្ថិតនៅភាគកើតស្ទឹងសៀមរាប និងតាមបណ្តោយផ្លូវជាតិលេខ៦កំពុងត្រូវបានពង្រីកយ៉ាងលឿន ហើយការសាងសង់ផ្លូវ និងប្រព័ន្ធបង្ហូរទឹកគួរតែធ្វើឡើងឱ្យបានលឿនតាមដែលអាចធ្វើបាន នៅពេលមានដី និងផ្លូវសមស្រប ។ AFDបានធ្វើការសិក្សាលទ្ធិលទ្ធភាព ហើយបានកំណត់គំរោងសំរាប់ផ្លូវថ្នល់ និងប្រព័ន្ធបង្ហូរទឹកជាអាទិភាពមួយចំនួន ។ ការសិក្សាលទ្ធិលទ្ធភាពនោះក៏បានបញ្ជាក់ពីតំរូវការបន្ទាន់សំរាប់ធ្វើការសិក្សាបន្ថែមដល់ស្ទឹងសៀមរាប និងប្រព័ន្ធបង្ហូរទឹកដ៏ធំក្នុងក្រុង ។

**ទំហំរូប/វិធីករបស់គំរោង និងកម្មវិធី :**

១. រៀបចំ និងសាងសង់ផ្លូវថ្នល់ និងប្រព័ន្ធបង្ហូរទឹកភ្លៀងដែលបានកំណត់ជាគំរោងអាទិភាពក្នុងការសិក្សាលទ្ធិលទ្ធភាព

២. ផែនការមេសំរាប់ប្រព័ន្ធបង្ហូរទឹកក្នុងតំបន់ក្រុងសៀមរាប និងអង្គរ

៣. សិក្សាលំអិតពីកំលាំងទឹក និងជលសាស្ត្រក្នុងស្ទឹងសៀមរាប ដោយរួមបញ្ចូលទាំងការគ្រប់គ្រង ការហូរច្រោះ និងកំណក

**គោលបំណងគំរោង :**

១. អនុវត្តគំរោងអាទិភាពដើម្បីកែលំអប្រព័ន្ធបង្ហូរទឹកភ្លៀង និងផ្លូវថ្នល់ក្នុងតំបន់ពង្រីកក្រុងដែលស្ថិត នៅភាគខាងកើតស្ទឹងសៀមរាប ។

**លទ្ធផលគំរោង :**

១. នាំទឹកភ្លៀងយ៉ាងប្រសិទ្ធភាពចេញពីផ្លូវថ្នល់ និងនាំតាមប្រឡាយបង្ហូរទឹកទៅកាន់តំបន់កសិកម្ម ២. ប្រឡាយបង្ហូរទឹកត្រូវស៊ីគ្នាទៅនឹងការសាងសង់ផ្លូវថ្នល់

៣. ផែនការមេសំរាប់ប្រព័ន្ធបង្ហូរទឹក និង ៤. ផែនការសកម្មភាពសំរាប់ការពារ និងគ្រប់គ្រងស្ទឹងសៀមរាប

**ឥទ្ធិពលលើសង្គម និងបរិស្ថាន :**

១. កាត់បន្ថយភ្នាក់ងារចំលងជំងឺផ្សេងៗ ដោយការលុបបំបាត់ទឹកដក់

២. កាត់បន្ថយផលប៉ះពាល់ទឹកភ្លៀងពីតំបន់ក្រុងលើតំបន់កសិកម្ម

៣. សំរួលការអភិវឌ្ឍទីតំបន់ពង្រីកក្រុង

**គំរោងពាក់ព័ន្ធ :**

SD-៤ : សំណើគំរោងប្រព័ន្ធបង្ហូរសំណល់រាវនៅសៀមរាប ដំណាក់កាល ២ ប្រឡាយបង្ហូរសំណល់រាវ និងរោងចក្រប្រព្រឹត្តិកម្មសំណល់រាវ

**កាលវិភាគអនុវត្ត :**

| | |
|---|---|
| ១. អនុម័តមូលនិធិ | ធ្នូ ០៥ |
| ២. រៀបចំលំអិតសំរាប់គំរោងអាទិភាព | មករា ០៦ - ធ្នូ ០៦ |
| ៣. ដេញថ្លៃ និងផ្តល់គំរោង | ធ្នូ ០៦ - មិថុនា ០៧ |
| ៤. សាងសង់ផ្លូវ និងប្រព័ន្ធបង្ហូរទឹក | មិថុនា ០៧ - មិថុនា ០៩ |
| ៥. ផែនការមេសំរាប់ប្រព័ន្ធបង្ហូរទឹក | មករា ០៦ - ធ្នូ ០៧ |
| ៦. សិក្សាល្បឿនទឹកស្ទឹងសៀមរាប | មករា ០៦ - ធ្នូ ០៧ |
| ៧. កសាងសមត្ថភាព | មករា ០៥ - ធ្នូ ០៩ |

**ការចំណាយលំអិតសំរាប់គំរោង ( ០០០ អ៊ីរ៉ូ ) :**

| | |
|---|---|
| ១. ផែនការមេ | ៤៥០ |
| ២. វិស្វកម្មលំអិត | ៣០០ |
| ៣. សាងសង់ | ៣.០០០ |
| ៤. កសាងសមត្ថភាព | ២៥០ |
| សរុប | ៤.០០០ |
| x ១.២ ( ដុល្លារ/អ៊ីរ៉ូ ) = | ៤.៨០០ |

| ល.កូត | ឈ្មោះគំរោង | អ្នកទទួលផល ឬក្រុមគោលដៅ | ថវិកាដែលបានសន្មត | តំលៃប៉ាន់ស្មាន | អាទិភាពគំរោង |
|---|---|---|---|---|---|
| P-1 | គំរោងសំរាប់ដាក់ម៉ាស៊ីនភ្លើងប្រើម៉ាស៊ូតជាបន្ទាន់ | ប្រជាជនមូលដ្ឋាន និងភ្ញៀវទេសចរនៅសៀមរាប | EdC | ២.០៥០ (000ដុល្លារ) | អាទិភាព |

| ទីតាំងគំរោង | ទីភ្នាក់ងារអនុវត្ត | មន្ទីរ | អ្នកទទួលទំនាក់ទំនង | ទូរស័ព្ទ | អីម៉ែល |
|---|---|---|---|---|---|
| ស្រុកសៀមរាប | EdC | មន្ទីរផែនការ | | | |

**ប្រវត្តិ :**

ដោយសារតំរូវការមានការកើនឡើងយ៉ាងលឿន ចាំបាច់ត្រូវបំពាក់ម៉ាស៊ីនភ្លើងបន្ថែមឱ្យបានលឿនបំផុតតាមដែលអាចធ្វើបាន។ ដើម្បីដោះស្រាយបញ្ហារយៈពេលខ្លី ចាំបាច់ត្រូវដំឡើងម៉ាស៊ីនភ្លើងប្រើម៉ាស៊ូតជាបណ្ដោះអាសន្ន។

**គោលបំណងគំរោង :**

*នៅពេលមានម៉ាស៊ីនភ្លើងដែលមានសមត្ថភាពប្រមាណជា ៧ មេហ្គាវ៉ាត់ វិបត្តិកង្វះថាមពលធ្ងន់ធ្ងរនឹងត្រូវបានដោះស្រាយ។*

**ទំរង់រូប/ផ្នែករបស់គំរោង និងកម្មវិធី :**

១. ផ្ដល់ប្រភេទម៉ាស៊ីនប្រើម៉ាស៊ូតដែលមានសមត្ថភាពសរុបប្រមាណជា ៧ មេហ្គាវ៉ាត់

២. ផ្ដល់ត្រែនស្វូ ៤០០វ៉ុល/២២គីឡូវ៉ុល

៣. ផ្ដល់សម្ភារៈបន្ថែមផ្សេងៗទៀត

៤. ដំឡើងម៉ាស៊ីនក្នុងបរិវេណ EdC

**លទ្ធផលគំរោង :**

សំរាប់ពេលបច្ចុប្បន្ន ការផ្គត់ផ្គង់ថាមពលសំរាប់ការរស់នៅរបស់ប្រជាជនក្នុងស្រុកគួរជាទីពេញចិត្ត តែប្រជាជនដែលរស់នៅក្នុងតំបន់មានអគ្គិសនីប៉ុណ្ណោះ។

**ឥទ្ធិពលលើសង្គម និងបរិស្ថាន :**

ផលប៉ះពាល់ដល់សង្គម និងបរិស្ថានតិចតួចមិនអាចគេចផុតបានឡើយ។

**គំរោងពាក់ព័ន្ធ :**

មិនទាន់បញ្ជាក់នៅឡើយ។

**កាលវិភាគអនុវត្ត :**

១. រៀបចំមូលនិធិ — មករា ០៦ - ធ្នូ ០៨

២. អនុវត្តគំរោង — មេសា ០៦ - កក្កដា ០៦

**ការចំណាយសំរាប់គំរោង (000 ដុល្លារ)**

១. ចំណាយផ្ទាល់ — ១.៩០០

២. កសាងសមត្ថភាព

៣. ប្រាក់បំរុងរូបវិន្ត

៤. ការបង្កើតតំលៃ — ១៥០

៥. សេវាកម្មវិស្វកម្ម

៦. មិញ្ញជី

សរុប — ២.០៥០

- អាចអនុវត្តកិច្ចសន្យាជួល

JICA - ការសិក្សាអំពីផែនការមេសម្រាប់ការអភិវឌ្ឍន៍ក្រុងសៀមរាប/អង្គរប្រកបដោយនិរន្តរភាព

សេចក្តីសង្ខេបគំរោង

វិស័យ : រដ្ឋបាលមូលដ្ឋាន

| ល.កូដ | ឈ្មោះគំរោង | អ្នកទទួលផល ឬក្រុមគោលដៅ | ថវិកាដែលបានសន្មត | តំលៃប៉ាន់ស្មាន | អាទិភាពគំរោង |
|---|---|---|---|---|---|
| LA-1 | បង្កើត និងដាក់ឱ្យដំណើរការគណៈកម្មការអភិវឌ្ឍន៍សំរាប់អនុម័តគំរោង | អាជ្ញាធរខេត្ត | គ្មាន | ១០០.០០០ ដុល្លារ | អាទិភាព |

| ទីតាំងគំរោង | ទីភ្នាក់ងារអនុវត្ត | មន្ទីរ | អ្នកទទួលទំនាក់ទំនង | ទូរស័ព្ទ | អ៊ីម៉ែល |
|---|---|---|---|---|---|
| ស្រុកសៀមរាប | អាជ្ញាធរខេត្តសៀមរាប | អាជ្ញាធរខេត្ត | | | |

**ប្រវត្តិ :**

១. កង្វះខាតលើការផ្តល់សេវាកម្មសាធារណៈមានសភាពធ្ងន់ធ្ងរ ជាពិសេសលើផ្នែកទាក់ទងនឹងបរិស្ថាន។ សេវាកម្មសាធារណៈ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈពុំទាន់មានភាពសមរម្យនៅឡើយ ដោយសារឧបសគ្គមួយចំនួន ដូចជា កង្វះខាតថវិកា កង្វះខាតតម្លាភាព និងគណនេយ្យភាពដើម្បីធានាការងារទាំងនោះ។ ២. ដំណើរការអនុម័តគំរោងបច្ចុប្បន្នមិនបានធានាឱ្យមានតម្លាភាពក្នុងចំណោមប្រជាជននៅមូលដ្ឋាន ដោយសារអាជ្ញាធរខេត្តដែលអនុវត្តការងារតាមប្រព័ន្ធរដ្ឋបាលបែបមជ្ឈការពុំមានការពាក់ព័ន្ធច្រើនក្នុងដំណើរការនេះ។ ៣. កង្វះខាតការសំរបសំរួលនៅថ្នាក់ខេត្តគឺជាបញ្ហាមួយក្នុងចំណោមបញ្ហាក្នុងការធ្វើឱ្យរលូននៃរដ្ឋបាលមូលដ្ឋាន។

**គោលបំណងគំរោង :**

ដើម្បីធ្វើសំរេចគោលបំណងខាងលើ គំរោងនេះស្នើបង្កើតគណៈកម្មការអភិវឌ្ឍន៍មួយនៅសៀមរាបដើម្បីអនុវត្តរដ្ឋបាលមូលដ្ឋានប្រកបដោយតម្លាភាព និងគណនេយ្យភាព។

**ទំរង់រូប/ផ្នែករបស់គំរោង និងកម្មវិធី :**

គណៈកម្មការអភិវឌ្ឍន៍ខេត្តសៀមរាបនឹងត្រូវបង្កើតឡើងតាមគំនិតផ្តួចផ្តើមរបស់អភិបាលខេត្តសៀមរាបដោយសហការជាមួយនឹងរដ្ឋាភិបាលនៅថ្នាក់ជាតិ និងអាជ្ញាធរអប្សរាដើម្បីដាក់ឱ្យដំណើរការរដ្ឋបាលមូលដ្ឋានមានភាពរលូន តម្លាភាព និងគណនេយ្យភាព។ ភារកិច្ច និងការទទួលខុសត្រូវរបស់គណៈកម្មការនេះមាន :

១. ពិនិត្យគំរោងអភិវឌ្ឍន៍នានា

២. វាយតំលៃ និងអនុម័តគំរោងអភិវឌ្ឍន៍ដែលបានស្នើឡើង

៣. សំរបសំរួលក្រសួង និងអ្នកផ្តល់ជំនួយផ្សេងៗ

៤. ធានាតម្លាភាពក្នុងដំណើរការអនុម័តគំរោង និង

៥. ពិនិត្យតាមដានគំរោងដើម្បីឱ្យមានគណនេយ្យភាព

**លទ្ធផលគំរោង :**

១. រដ្ឋបាលមូលដ្ឋានស្វយ័ត និងរលូនស្របទៅតាមកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ

២. តម្លាភាព និងគណនេយ្យភាព

**ឥទ្ធិពលលើសង្គម និងបរិស្ថាន :**

១. ចូលរួមដល់ការលើកកំពស់បរិស្ថានតាមរយៈដំណើរការអនុម័តគំរោងដោយមានគោលនយោបាយបរិស្ថានរបស់សៀមរាបផង

២. ជួយលើកកំពស់សមធម៌សង្គមតាមរយៈដំណើរការប្រកបដោយតម្លាភាព។

**គំរោងពាក់ព័ន្ធ :**

L-2 កំណែទំរង់ការគ្រប់គ្រងនៃអាជ្ញាធរខេត្ត

**កាលវិភាគអនុវត្ត :**

២០០៦-២០១២

**ការចំណាយលំអិតរាប់គំរោង (០០០ ដុល្លារ)**

| | |
|---|---|
| ការអភិវឌ្ឍន៍សមត្ថភាព | ១០០ |
| សរុប | ១០០ |

**JICA - ការសិក្សាអំពីផែនការមេរួមសំរាប់ការអភិវឌ្ឍន៍ក្រុងសៀមរាប/អង្គរប្រកបដោយនិរន្តរភាព**

**សេចក្តីសង្ខេបគំរោង**

**វិស័យ : រដ្ឋបាលមូលដ្ឋាន**

| លេ.កូដ | ឈ្មោះគំរោង | អ្នកទទួលផល ឬក្រុមគោលដៅ | ថវិកាដែលបានសន្មត | តំលៃប៉ាន់ស្មាន | អាទិភាពគំរោង |
|---|---|---|---|---|---|
| LA-2 | ការអភិវឌ្ឍន៍ធនធានមនុស្សសំរាប់អាជ្ញាធរខេត្តសៀមរាប | អាជ្ញាធរខេត្ត | ជំនួយបរទេស | ១.៦លានដុល្លារ | អាទិភាព |

| ទីតាំងគំរោង | ទីភ្នាក់ងារអនុវត្ត | មន្ទីរ | អ្នកទទួលទំនាក់ទំនង | ទូរស័ព្ទ | អ៊ីមែល |
|---|---|---|---|---|---|
| ខេត្តសៀមរាប | អាជ្ញាធរខេត្តសៀមរាប | អាជ្ញាធរខេត្ត | | | |

**ទីតាំងគំរោង**

សមត្ថភាពអាជ្ញាធរខេត្តសៀមរាបពុំទាន់មានភាពរឹងមាំលើផ្នែករដ្ឋបាលមូលដ្ឋាននៅឡើយ ជាពិសេសសំរាប់ការគ្រប់គ្រង និងប្រតិបត្តិនៃសេវាកម្មសាធារណៈ។ ប្រការនេះដោយសារកង្វះខាតសមត្ថភាពបច្ចេកទេស ដែលមិនទាន់ត្រៀមខ្លួនរួចរាល់ដើម្បីអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅឡើយ។

**គោលបំណងគំរោង**

គោលបំណងរបស់គំរោង គឺដើម្បីពង្រឹងសមត្ថភាពមន្ត្រីអាជ្ញាធរខេត្តសំរាប់ផ្តល់សេវាកម្មសាធារណៈសំខាន់ៗ ដោយការត្រៀមខ្លួនសំរាប់អនុវត្តគោលនយោបាយវិមជ្ឈការ។

**ទំហំរួម/ផ្នែករបស់គំរោង និងកម្មវិធី :**

១. ពង្រឹងសមត្ថភាពបច្ចេកទេសដើម្បីធ្វើផែនការ និងអនុវត្តគំរោង ដូចជាការវិភាគស្ថិតិ រៀបចំទិន្នន័យ និងការគ្រប់គ្រង និងត្រួតពិនិត្យគំរោង

២. ពង្រឹងសមត្ថភាពក្នុងការផ្សព្វផ្សាយគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ

**លទ្ធផលគំរោង :**

១. ពង្រឹងធនធានមនុស្សសំរាប់អនុវត្តសេវាកម្មសាធារណៈ ២. ពង្រឹងធនធានមនុស្សសំរាប់រដ្ឋបាលមូលដ្ឋានសមស្រប ៣. ពង្រឹងធនធានមនុស្សដែលចាំបាច់សំរាប់រដ្ឋបាលមូលដ្ឋានស្វយ័ត និងរលូន ស្របតាមកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ។

**ផលប៉ះពាល់លើសង្គម និងបរិស្ថាន :**

ចូលរួមដល់ការលើកកំពស់បរិស្ថានតាមរយៈសមត្ថភាពដែលបានពង្រឹងដើម្បីអនុវត្តការងារសាធារណៈ។

**កាលវិភាគអនុវត្ត :**

២០០៦-២០១២

**ការចំណាយសំរាប់គំរោង (០០០ ដុល្លារ)**

| | |
|---|---|
| ការអភិវឌ្ឍន៍សមត្ថភាព | ១.៦០០ |
| សរុប | ១.៦០០ |

**គំរោងពាក់ព័ន្ធ**

១. LA-2 កំណែទំរង់ការគ្រប់គ្រងនៃអាជ្ញាធរខេត្ត ២. កម្មវិធីសិលា ៣. ការកសាងសមត្ថភាពសំរាប់កម្មវិធីសហប្រតិបត្តិការបច្ចេកទេសរបស់ JICA (២០០៦-២០០៨/៩)


jica